ARISE+

ASEAN Intellectual Property Rights

# ពិធីសារទីក្រុងម៉ាឌ្រីដ

សៀវភៅមគ្គុទេសក៍អនុវត្ត
សម្រាប់សហគ្រិនកម្ពុជា

វិធីឆ្ពោះទៅរកការកសាង
ម៉ាកយីហោជាសកល

Funded by the European Union

EUIPO
EUROPEAN UNION
INTELLECTUAL PROPERTY OFFICE

# ពិធីសារទីក្រុង ម៉ាឌ្រីដ


**ប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា**
ផ្ទះលេខ ១០០អា មហាវិថី ព្រះនរោត្តម
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៧
ព្រះរាជាណាចក្រកម្ពុជា
+៨៥៥ ២៣ ២១៦ ៩៩៦/ ២២០ ៦១១
DELEGATION-CAMBODIA@eeas.europa.eu

**នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា**
www.cambodiaip.gov.kh
cambodiaip.dip@gmail.com

**ARISE+ IPR**
www.ariseplusipr.eu
@ARISEplus_IPR
Arise+IPR@euipo.europa.eu



កូនសៀវភៅនេះត្រូវបានរៀបរៀងដោយគម្រោង ARISE + IPR សហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា(DIP) នៃក្រសួងពាណិជ្ជកម្ម នៃប្រទេសកម្ពុជា និងមានជំនួយពីទីប្រឹក្សាអន្តរជាតិ លោក Ernesto Rubio ។ ខ្លឹមសារនៃកូនសៀវភៅនេះគឺជាការទទួលខុសត្រូវតែមួយគត់របស់គម្រោង ARISE + IPR ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុប ឬការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប(EUIPO)ទេ - នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ខែធ្នូ ឆ្នាំ ២០១៨ ។

# មាតិកា


| | |
|---|---|
| អំពីកម្មវិធី ARISE+ IPR | 5 |
| បុព្វកថាពីប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា | 6 |
| បុព្វកថាពីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា | 7 |
| **1. ម៉ាកយីហោរបស់អ្នក ទ្រព្យសម្បត្តិដ៏រឹងមាំរបស់អ្នក** | 9 |
| 1.1. យុទ្ធសាស្ត្រកសាងម៉ាកយីហោ និងភាពជោគជ័យលើអាជីវកម្ម | 9 |
| 1.2. ការបង្កើតម៉ាកយីហោ ការគ្រប់គ្រង និងការធ្វើអាជីវកម្ម | 9 |
| 1.3. ការការពារម៉ាកយីហោអ្នកក្នុងទីផ្សារនាំចេញ | 9 |
| **2. ពិធីសារទីក្រុងម៉ាឌ្រីដ - ដំណោះស្រាយច្រកតែមួយដើម្បីការពារម៉ាកយីហោរបស់អ្នកនៅបរទេស** | 10 |
| 2.1. សមាជិកសហភាពម៉ាឌ្រីដ ទីផ្សារទាក់ទាញសម្រាប់ការនាំចេញរបស់កម្ពុជា | 10 |
| 2.2. ពិធីសារទីក្រុងម៉ាឌ្រីដ និងនីតិវិធីងាយស្រួល | 11 |
| 2.2.1. ការដាក់ពាក្យកណ្តាលដើម្បីស្វែងរកការការពារក្នុងដែនដីផ្សេងៗ | 11 |
| 2.2.2. ការគ្រប់គ្រងកណ្តាលសម្រាប់ម៉ាករបស់អ្នក | 11 |
| 2.3. គុណសម្បត្តិ តម្លៃត្រូវបានកាត់បន្ថយ ការគ្រប់គ្រងម៉ាកយីហោ និងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព | 11 |
| **3. ការជ្រើសរើសម៉ាករបស់អ្នក ការអនុវត្តល្អៗ** | 13 |
| 3.1. ការស្រាវជ្រាវម៉ាកក្នុងប្រទេសកម្ពុជា | 14 |
| 3.2. ការស្រាវជ្រាវសម្រាប់ម៉ាកនៅបរទេស ប្រព័ន្ធទិន្នន័យអនឡាញ (ASEAN TMVIEW, TMVIEW, Global Brands) | 14 |
| **4. ការរៀបចំ និងដាក់ពាក្យស្នើសុំម៉ាកជាអន្តរជាតិ ការអនុវត្តដ៏ល្អៗ** | 15 |
| 4.1. សេចក្តីតម្រូវ ការទទួលសិទ្ធិ ម៉ាកគោលក្នុងប្រទេសកម្ពុជា | 15 |
| 4.2. ការដាក់ពាក្យស្នើសុំជាអន្តរជាតិនៅ DIP | 15 |
| 4.3. មាតិកានៃពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក បទបញ្ញា ឬតាមជម្រើស | 15 |
| 4.4. ការទាញយកបញ្ជីទំនិញ និងសេវារបស់អ្នក ការប្រើឧបករណ៍ចាត់ចំណាត់ថ្នាក់ (TMclass, ASEAN TMCLASS, MGS) | 16 |
| 4.5. ការជ្រើសរើសយកដែនដីដែលជាកន្លែងទទួលបានការការពារ | 17 |
| 4.6. ការប៉ាន់ស្មានតម្លៃ និងការបង់កម្រៃ ការគណនាថ្លៃម៉ាឌ្រីដ មធ្យោបាយបង់ប្រាក់ | 18 |
| 4.7. ការបញ្ជាក់ដោយ DIP និង ការដោះស្រាយភាពមិនប្រក្រតីដែលអាចកើតមាន | 19 |

ARISE+
ASEAN Intellectual Property Rights


| | | |
|---|---|---|
| 5. | **ការចុះបញ្ជីម៉ាកជាអន្តរជាតិ (IR)** | 20 |
| 5.1. | កាលបរិច្ឆេទ និងប្រសិទ្ធភាព | 20 |
| 5.1.1. | កាលបរិច្ឆេទនៃការចុះបញ្ជីជាអន្តរជាតិ | 20 |
| 5.1.2. | ប្រសិទ្ធភាពនៃការចុះបញ្ជីជាអន្តរជាតិ | 20 |
| 5.2. | គ្រប់គ្រងការចុះបញ្ជីជាអន្តរជាតិរបស់អ្នក ការអនុវត្តល្អៗ | 21 |
| 5.2.1 | ការពង្រីកការការពារនៅក្នុងដែនដីថ្មី (ការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម) | 21 |
| 5.2.2 | ការកត់ត្រាកណ្តាលលើការកែប្រែការចុះបញ្ជីជាអន្តរជាតិរបស់អ្នក | 22 |
| 5.2.3 | ការចុះបញ្ជីជាអន្តរជាតិរបស់អ្នកសារឡើងវិញ | 23 |
| 5.3. | ភាពមិនឯករាជ្យ និងការប្រែប្រួលក្នុងរយៈពេលពេលប្រាំឆ្នាំ ភាពឯករាជ្យបន្ទាប់ពីរយៈពេលប្រាំឆ្នាំ | 24 |
| 5.4. | ឧបករណ៍អេឡិចត្រូនិកដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងការចុះបញ្ជីម៉ាកជាអន្តរជាតិ | 25 |
| 5.4.1. | ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធម៉ាឌ្រីដ | 25 |
| 5.4.2. | ប្រព័ន្ធគ្រប់គ្រងប្រវត្តិឯកសារម៉ាឌ្រីដ(MPM) | 25 |
| 6. | **ការការពារម៉ាករបស់អ្នកនៅក្នុងសហភាពអឺរ៉ុប** | 26 |
| 6.1. | ការដាក់ដោយផ្ទាល់ទៅកាន់ EUIPO(ប្រកថ្នាក់តំបន់អឺរ៉ុប) | 26 |
| 6.2. | ការជ្រើសរើសយក EU តាមរយៈប្រព័ន្ធម៉ាឌ្រីដ (ប្រកថ្នាក់អន្តរជាតិ) និងការអនុវត្តល្អៗ | 27 |
| 6.2.1. | ការជ្រើសរើសយកសហភាពអឺរ៉ុប និងលក្ខខណ្ឌតម្រូវដាក់លាក់ | 27 |
| 6.2.2. | ការតំណាងវិជ្ជាជីវៈនៅចំពោះមុខ EUIPO | 28 |
| 6.2.3. | ការបោះពុម្ពឡើងវិញលើកដំបូង ការស្រាវជ្រាវ និងត្រួតពិនិត្យបែបបទ | 28 |
| 6.2.4. | ការត្រួតពិនិត្យអំពីមូលដ្ឋានដាច់ខាតសម្រាប់ការបដិសេធ | 29 |
| 6.2.5. | ការប្តឹងជំទាស់ | 29 |
| 6.2.6. | សេចក្តីសម្រេចចុងក្រោយ | 30 |
| 6.2.7. | ការបោះពុម្ពឡើងវិញជាលើកទី ២ និងការការពារនៅក្នុង EU | 30 |
| 6.2.8. | ការផ្លាស់ប្តូរទៅជា EUTM | 30 |
| 6.2.9. | ការបម្លែង | 31 |
| 6.2.10. | ការជំនួសនៅក្នុង EU | 31 |
| 7. | **សេចក្តីសន្និដ្ឋាន** | 31 |
| | **ឧបសម្ព័ន្ធ** | |
| | សមាជិកសហភាពពិធីសារទីក្រុងម៉ាឌ្រីដ | 32 |
| | អក្សរកាត់ | 33 |
| | សទ្ទានុក្រម | 33 |
| | ឧបករណ៍អនឡាញ និងសេវាផ្សេងៗដែលអាចរកបានដោយសេរីសម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធម៉ាឌ្រីដ | 34 |

## អំពីកម្មវិធី ARISE+IPR

កម្មវិធី ARISE Plus សម្រាប់វិស័យកម្មសិទ្ធិបញ្ញា (ARISE + IPR) គឺជាសមាសធាតុមួយក្រោមជំនួយឧបត្ថមពង្រឹងសមាហរណកម្មតំបន់អាស៊ានរបស់សហភាពអឺរ៉ុប (EU) ឬ ហៅកាត់ថា ARISE Plus ។ កម្មវិធី ARISE+ IPR មានទឹកប្រាក់ចំនួន ៥,៥លានអឺរ៉ូ សម្រាប់រយៈពេល៥ឆ្នាំដើម្បីជួយដល់ការធ្វើសមាហរណកម្មក្នុងតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (IP) និងក្នុងគោលបំណងដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកម្មសិទ្ធិបញ្ញា សម្រាប់ការបង្កើត ការការពារ ការប្រើប្រាស់ ការគ្រប់គ្រង និងការអនុវត្តន៍ច្បាប់ ឲ្យស្របជាមួយការអនុវត្តន៍ល្អៗ និងមាត្រដ្ឋានអន្តរជាតិ និងគោលដៅយុទ្ធសាស្រ្តផែនការសកម្មភាពកម្មសិទ្ធិបញ្ញរបស់អាស៊ានឆ្នាំ ២០១៦-២០២៥ ។

ARISE+IPR មានគោលបំណងដើម្បី:

- បង្កើនការចូលរួមរបស់រដ្ឋជាសមាជិកអាស៊ាននៅក្នុងសន្ធិសញ្ញាកម្មសិទ្ធិបញ្ញអន្តរជាតិ និងប្រព័ន្ធជាសកល
- ចូលរួមចំណែកក្នុងការកសាងសមត្ថភាពស្ថាប័នឆ្ពោះទៅរកការិយាល័យ IP របស់អាស៊ានដែលមានប្រសិទ្ធិភាពខ្ពស់
- បង្កើនការយល់ដឹងផ្នែកនយោបាយនិងសាធារណៈអំពីសារៈសំខាន់នៃការការពារនិងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា
- ពង្រឹងសមត្ថភាពរបស់ធុរកិច្ចអាស៊ានឲ្យទៅជាពាណិជ្ជកម្ម និងការពារសិទ្ធិកម្មសិទ្ធិបញ្ញរបស់ពួកគេ
- ផ្តល់ការគាំទ្រតាមតម្រូវការដល់ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា

ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋជាសមាជិកអាស៊ាននិងលេខាធិការដ្ឋានអាស៊ាន កម្មវិធី ARISE+IPR បានបញ្ចូលបន្ថែមនូវអត្ថប្រយោជន៍នៃការការពារកម្មសិទ្ធិបញ្ញាយ៉ាងរឹងមាំនៅក្នុងតំបន់ ។ តាមរយៈគំនិតផ្តួចផ្តើមកសាងសមត្ថភាពការអភិវឌ្ឍន៍ឧបករណ៍ព័ត៌មានវិទ្យា ការផ្លាស់ប្តូរការអនុវត្តន៍ល្អៗ ការអនុម័តមាត្រដ្ឋានអន្តរជាតិនិងយុទ្ធនាការលើកកម្ពស់ការយល់ដឹងដើម្បីលើកការប្រើប្រាស់ កិច្ចការពារ និងការអនុវត្តន៍ច្បាប់សិទ្ធិកម្មសិទ្ធិបញ្ញា កម្មវិធីនេះ សបញ្ជាក់ពីលទ្ធផលប្រសើរឡើងសម្រាប់ ការគ្រប់គ្រង ភ្នាក់ងារអនុវត្តច្បាប់ ការធ្វើពាណិជ្ជកម្មក្នុងប្រទេស និងអន្តរជាតិក្នុងវិស័យកម្មសិទ្ធិបញ្ញា ក៏ដូចជាសាធារណជនទូទៅរវាងសហគមន៍អឺរ៉ុប និងអាស៊ាន។

កម្មវិធី ARISE+IPR ធ្វើការឆ្ពោះទៅរកការបង្កើតឲ្យមានការអភិវឌ្ឍន៍របបកម្មសិទ្ធិបញ្ញាដ៏ខ្លាំងមួយ តាមរយៈរដ្ឋជាសមាជិកអាស៊ាន ដែលជម្រុញការបង្កើតថ្មី ពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងតំបន់។

ARISE+
ASEAN Intellectual Property Rights

# បុព្វកថា ពី ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា

សហភាពអឺរ៉ុប (EU) គាំទ្រយ៉ាងពេញទំហឹងដល់ការការពារនិងពង្រឹងការអនុវត្តច្បាប់ កម្មសិទ្ធិបញ្ញា (IP) រួមមានទាំងពាណិជ្ជសញ្ញាផងដែរ។ ប្រព័ន្ធការពារ កម្មសិទ្ធិបញ្ញា គឺជាមូលដ្ឋានគ្រឹះនៃគោលនយោបាយសេដ្ឋកិច្ចសម័យទំនើប និងជាកត្តាជំរុញដល់ការអភិវឌ្ឍ។ ប្រព័ន្ធការពារ កម្មសិទ្ធិបញ្ញា អនុញ្ញាតឱ្យមានការអភិវឌ្ឍសមត្ថភាពបច្ចេកវិជ្ជាក្នុងស្រុក និងទាញយកឱកាសនាំចេញដោយការពង្រឹងភាពប្រកួតប្រជែង។

កិច្ចការពារសិទ្ធិ កម្មសិទ្ធិបញ្ញា រួមទាំងពាណិជ្ជសញ្ញា គឺជាគន្លឹះក្នុងការជម្រុញបង្កើនពាណិជ្ជកម្មទ្វេភាគី រវាង **EU-ASEAN** ដែលមានទំហំទឹកប្រាក់រហូតដល់ ២០១.១ប៊ីលានអឺរ៉ូ ក្នុងឆ្នាំ២០១៧។ ប្រព័ន្ធការពារកម្មសិទ្ធិបញ្ញាដ៏រឹងមាំងមួយលើកទឹកចិត្តដល់ នវានុវត្តន៍ ជានានូវការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ចទៅដល់អ្នកបង្កើតស្នាដៃ បង្កើនទំនុកចិត្តដល់អ្នកវិនិយោគ ដែលជាហេតុនាំដល់ការរីកចម្រើន សេដ្ឋកិច្ច និង បង្កើនការងារ។

ប្រទេសកម្ពុជា ជាច្រើនសតវត្សមកហើយ មានសមត្ថភាពជាច្រើន ក្នុងការផ្តល់ជូននូវស្នាដៃច្នៃប្រឌិត ក្នុងវិស័យសិប្បកម្ម និងកសិកម្ម ។ ថ្មីៗនេះ ប្រទេសកម្ពុជាបានក្លាយទៅជាគោលដៅវិនិយោគសម្រាប់ឧស្សាហកម្មដែលពឹងផ្អែកលើការការពារម៉ាកយីហោតាមរយៈសិទ្ធិពាណិជ្ជសញ្ញានិងបច្ចេកវិទ្យាដែលត្រូវបានការពារដោយប្រកាសនីយប័ត្រតក្កកម្មនិងគំនូរឧស្សាហកម្ម។ ក្រុមហ៊ុនរបស់កម្ពុជាក៏កំពុងចាប់ផ្តើមអភិវឌ្ឍម៉ាកយីហោរបស់ខ្លួនផងដែរ។ នេះគឺជាមធ្យោបាយឆ្ពោះទៅមុខក្នុងសតវត្សទី ២១ក្នុងវិស័យ សេដ្ឋកិច្ចចំនេះដឹង ។

ជាការពិតណាស់ការផ្តល់នូវការការពារ និងការអនុវត្តកម្មសិទ្ធិបញ្ញា ដែលមានបទដ្ឋានខ្ពស់និងទាក់ទាញវិនិយោគចូលមកក្នុងស្រុកនិងបរិក្ខាផលិតកម្មដែលអាចទទួលបានបច្ចេកវិទ្យាបរទេសមានឥទ្ធិពលយ៉ាងខ្លាំងដល់កំណើនផលិតភាពនៅក្នុងបណ្តាប្រទេសនៃតំបន់នេះ។ និយាយឱ្យសាមញ្ញ អ្នកវិនិយោគនិងក្រុមហ៊ុនក្នុងពិភពលោកនឹងមិននាំផលិតផល សេវាកម្ម នឹង ការច្នៃប្រឌិតទៅកាន់ទីផ្សារដែលគ្មានប្រព័ន្ធការពារពាណិជ្ជសញ្ញា ដ៏រឹងមាំនោះទេ។

ចំនុចសំខាន់សម្រាប់ពិចារណាមួយសម្រាប់ម្ចាស់ពាណិជ្ជសញ្ញា ជាពិសេស សម្រាប់សហគ្រាសធុន តូចបំផុត តូច និងមធ្យម **(MSMEs)** នោះគឺ មធ្យោបាយចំណាយដ៏មានប្រសិទ្ធិភាពជាងគេ ក្នុងការដាក់ពាក្យ និងការពារម៉ាករបស់ពួកគេនៅក្រៅប្រទេស។សហគ្រិននៅកម្ពុជាអាចទទួលបានផលប្រយោជន៍ពី ការចុះបញ្ជីជាលក្ខណៈអន្តរជាតិតាមប្រព័ន្ធម៉ាទ្រីដ **(Madrid System) ដែល**ផ្តល់នូវភាពសាមញ្ញ ងាយស្រួល និងការចំណាយប្រកបដោយប្រសិទ្ធិភាព ដើម្បីចុះបញ្ជី និងគ្រប់គ្រងម៉ាកបានរហូតដល់ទៅ ១១៩ ប្រទេស ដោយប្រើពាក្យស្នើសុំតែមួយដែលមានតែមួយភាសា សម្រាប់ច្រើនប្រទេស និង បង់ថ្លៃចំណាយតែមួយកញ្ចប់ជាការស្រេច។ ការកំហិតពេលវេលាដ៏តឹងរ៉ឹងក្នុងដំណើរការការចុះបញ្ជី មានន័យថាម្ចាស់ធុរកិច្ចទទួលបានយ៉ាងឆាប់រហ័សនូវការការពារពាណិជ្ជសញ្ញាជាអន្តរជាតិ។

ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃពិធីសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកអន្តរជាតិនៅថ្ងៃទី ៥ ខែមិថុនាឆ្នាំ ២០១៥ ។ ប្រព័ន្ធម៉ាឌ្រីដលើកទឹកចិត្តវិនិយោគទុនបរទេសចូលមកប្រទេសកម្ពុជាដោយធ្វើឱ្យកាន់តែមានភាពងាយស្រួលសម្រាប់អាជីវកម្មក្នុងការការពារពាណិជ្ជសញ្ញាបស់ពួកគេនៅទីនេះ និងបង្កើនទំនុកចិត្តរបស់វិនិយោគិននិង ពាណិជ្ជកម្ម។ ។ ដូចគ្នានេះដែរប្រព័ន្ធម៉ាឌ្រីដក៏ធ្វើឱ្យអាជីវកម្មរបស់ប្រទេសកម្ពុជា មានភាពងាយស្រួលក្នុងការពង្រីកការការពារម៉ាកយីហោរបស់ពួកគេនៅក្រៅប្រទេសដែលសម្រួលដល់ឱកាសនាំចេញ។

កូនសៀវភៅនេះ "**ពិធីសារទីក្រុងម៉ាឌ្រីដ: ច្រកចេញចូលឆ្ពោះទៅរកការការពារម៉ាកយីហោជាសកល**" គឺជាសៀវភៅមគ្គទេសក៏ដ៏ទូលំទូលាយសម្រាប់អាជីវកម្មទាំងឡាយនៅក្នុងប្រទេសកម្ពុជា ដែលមានបំណងរក្សាការពារម៉ាករបស់ខ្លួនជាលក្ខណៈអន្តរជាតិ, ផ្តល់ព័តមានលម្អិតអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធម៉ាទ្រីដ,និតីវិធី និង តម្លៃ, លក្ខខណ្ឌតម្រូវក្នុងស្រុក, និងគន្លឹះមួយចំនួនសម្រាប់ការអភិវឌ្ឍម៉ាក ក្នុងចំណោមអត្ថប្រយោជន៍ជាច្រើនទៀត នៃការចុះបញ្ជីម៉ាក។

ជំពួមួយស្តីពី ការការពារម៉ាកនៅក្នុងសហភាពអឺរ៉ុប រំលេចអំពីអត្ថប្រយោជន៍ នៃការចុះបញ្ជី ពាណិជ្ជសញ្ញាសហភាពអឺរ៉ុប **(EUTM)** ដែលផ្តល់ជូននូវការការពារ ក្នុងប្រទេសសមាជិកសហភាពអឺរ៉ុបទាំង២៨ ។

សហភាពអឺអឺរ៉ុបនឹងបន្តកិច្ចសហប្រតិបត្តិការដ៏មានផ្លែផ្កានេះជាមួយប្រទេសកម្ពុជាដើម្បីសម្រួលដល់បរិស្ថានធុរកិច្ច ឲ្យដំណើរការទៅប្រកបដោយវិជ្ជមាននិងជំរុញកិច្ចការពារ ការធានា និងការលើកទឹកចិត្តដល់ពាណិជ្ជករ និងអ្នកបង្កើតស្នាដៃ ។

**ចច អេដហ្គា**
ឯកអគ្គរដ្ឋទូតនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា

## បុព្វកថាពីនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា

នាយកដ្ឋានកម្មសិទ្ធិបញ្ញា (DIP) នៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា (SNCIP) បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចុះបញ្ជីម៉ាកតាំងពីឆ្នាំ១៩៩១ មកម្លេះ ដោយអនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជាសមាជិកពិធីសារទាក់ទង និងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកជាអន្តរជាតិ ចាប់តាំងពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥ និងបានចាប់ផ្តើមអនុវត្តការចុះបញ្ជីម៉ាកជាអន្តរជាតិផងដែរ។

កម្មវិធី ARISE Plus គឺត្រូវបានអនុវត្តដោយការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប ដើម្បីគាំទ្រសមាហរណកម្មតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធកម្មសិទ្ធិបញ្ញា សម្រាប់ការច្នៃប្រឌិត ការការពារ ការប្រើប្រាស់ ការគ្រប់គ្រង និងការអនុវត្តច្បាប់ ឲ្យស្របតាមការអនុវត្តអន្តរជាតិល្អៗ និងតាមមាត្រដ្ឋាន និងផែនការសកម្មភាពយុទ្ធសាស្ត្ររបស់អាស៊ាន ២០១៦ ដល់ ២០២៥។

ក្រោមសកម្មភាពទី១១ នៃកម្មវិធី ARISE Plus ដែលមានកិច្ចសហប្រតិបត្តិការជាមួយ DIP ដើម្បីរៀបចំកូនសៀវភៅម៉ាឌ្រីដ "ពិធីសារទីក្រុងម៉ាឌ្រីដ" វិថីឆ្ពោះទៅរកការកសាងម៉ាកយីហោជាសកល ដែលជាសៀវភៅមគ្គុទេសក៍ដ៏ទូលំទូលាយមួយសម្រាប់ការធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ក្នុងបំណងការពារពាណិជ្ជសញ្ញាជាអន្តរជាតិ គុណសម្បត្តិលម្អិតនៃប្រព័ន្ធពិធីសារទីក្រុងម៉ាឌ្រីដ នីតិវិធីនិងកម្រៃ ការតម្រូវ និងគន្លឹះអភិវឌ្ឍន៍ម៉ាកយីហោ ក្នុងចំណោមទិដ្ឋភាពដែលមានប្រយោជន៍ជាច្រើននៃការចុះបញ្ជីពាណិជ្ជសញ្ញា។

DIP និង SNCIP សូមឆ្លៀតយកឱកាសនេះដើម្បីបង្ហាញពីការដឹងគុណដ៏ស្មោះរបស់ EUIPO សម្រាប់ការផ្តល់នូវការអភិវឌ្ឍន៍បច្ចេកទេស ច្បាប់ ផ្នែកធនធានមនុស្ស និងប្រព័ន្ធ IP នៅក្នុងប្រទេសកម្ពុជា និងកំពុងទន្ទឹងរង់ចាំបន្តកិច្ចសហប្រតិបត្តិការជាមួយ EUIPO និងអាស៊ានដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ និងកិច្ចការពារ IPRs និងលើកទឹកចិត្តសកម្មភាពអាជីវកម្មនៅក្នុងប្រទេសកម្ពុជា សហភាពអឺរ៉ុប និងតំបន់អាស៊ាន។

**លោក អប់ វ៉ាឌី**
ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា

ARISE+
ASEAN Intellectual Property Rights

# 1. ម៉ាកយីហោរបស់អ្នក ទ្រព្យសម្បត្តិដ៏រឹងមាំរបស់អ្នក

ម៉ាកយីហោរបស់អ្នកគឺរូបភាពដែលធ្វើឲ្យមានភាពខុសគ្នារវាងអ្នកនឹងដៃគូប្រកួតប្រជែងរបស់អ្នក។ វាកំណត់អត្តសញ្ញាណផលិតផលរបស់អ្នក សេវារបស់អ្នក ក្រុមហ៊ុនរបស់អ្នក។ វាអាចជាតំណាងដោយសញ្ញាមួយ និមិត្តសញ្ញាមួយ ការរចនាមួយ ពាក្យមួយ ពណ៌មួយ ឬការរួមបញ្ចូលគ្នា។ វាបង្ហាញឲ្យដឹងពីគុណភាព ភាពជឿទុកចិត្ត និងភាពពេញចិត្តរបស់អតិថិជន។ វាដើរតួយ៉ាងសំខាន់ក្នុងយុទ្ធសាស្ត្រទីផ្សាររបស់អ្នក និងជាចំណុចស្នូលនៃការប្រកួតប្រជែងអាជីវកម្មរបស់អ្នក។ វាបង្កើតឲ្យមានអតិថិជនដែលមានភាពស្មោះត្រង់ និងគុណតម្លៃ។ វាអាចក្លាយទៅជាទ្រព្យសម្បត្តិដ៏រឹងមាំរបស់អ្នក។

## 1.1. យុទ្ធសាស្ត្រកសាងម៉ាកយីហោ និងភាពជោគជ័យលើអាជីវកម្ម

ការកសាងម៉ាកយីហោសំដៅលើការបង្កើតឲ្យមានភាពព្រៃកដាច់ និងទាក់ទាញនៅក្នុងទីផ្សារ ដែលជួយពង្រីក និងរក្សាជំនឿពីអតិថិជន។ ប្រសិទ្ធភាពការកសាងម៉ាកយីហោទាក់ទងនឹងការបង្កើតរូបភាពក្នុងផ្នត់គំនិតរបស់អតិថិជន អំពីគុណភាពផលិតផល ឬសេវា ជាចំបងតាមរយៈយុទ្ធនាការផ្សព្វផ្សាយពាណិជ្ជកម្មផ្តោតលើម៉ាកយីហោ។ វាក៏តម្រូវឲ្យមានការធានាការពារផ្នែកច្បាប់នៃម៉ាកយីហោប្រឆាំងទៅនឹងដៃគូប្រកួតប្រជែងនៅក្នុងទីផ្សារណាមួយ។ យុទ្ធសាស្ត្រកសាងម៉ាកយីហោ គឺជាចំណុចស្នូលនៃការប្រកួតប្រជែងទីផ្សារប្រកបដោយនិរន្តរភាព និងភាពជោគជ័យលើអាជីវកម្ម។

## 1.2. ការបង្កើតម៉ាកយីហោ ការគ្រប់គ្រង និងការធ្វើអាជីវកម្ម

ការបង្កើតម៉ាកយីហោមួយសំដៅលើការជ្រើសរើសយកសញ្ញាដែលសម្គាល់លក្ខណៈខុសគ្នាចំពោះផលិតផល ឬសេវារបស់អ្នកពីដៃគូប្រកួតប្រជែងរបស់អ្នក និងទទួលបានការការពារដោយច្បាប់។ ការបង្ហាញភាពស្របច្បាប់ចំពោះម៉ាកយីហោរបស់អ្នកគឺជាម៉ាក។ ម៉ាកមួយផ្តល់ឲ្យអ្នកនូវសិទ្ធិផ្តាច់មុខក្នុងការរារាំងភាគីទីបីពីការប្រើសញ្ញា ដែលសម្គាល់លក្ខណខុសគ្នាចំពោះម៉ាកយីហោរបស់អ្នកក្នុងការធ្វើពាណិជ្ជកម្មសម្រាប់ទំនិញ ឬសេវាដូចគ្នា ឬស្រដៀងគ្នា។

អ្នកអាចចុះបញ្ជីម៉ាករបស់អ្នកនៅក្នុងប្រទេសកម្ពុជាដោយធ្វើការដាក់ពាក្យស្នើសុំនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា (DIP) នៃក្រសួងពាណិជ្ជកម្ម។ ការការពារម៉ាករបស់អ្នកនៅកម្ពុជាមានរយៈពេល ១០ ឆ្នាំ ហើយអាចធ្វើការចុះបញ្ជីសាឡើងវិញដោយមិនកំណត់សម្រាប់ក្នុងរយៈពេលការពារដូចគ្នា។ ការគ្រប់គ្រងម៉ាកយីហោរបស់អ្នកសំដៅលើការចុះបញ្ជីសាឡើងវិញចំពោះម៉ាករបស់អ្នកជាទៀងទាត់ និងការអនុវត្តសិទ្ធិរបស់អ្នកប្រឆាំងទៅនឹងអ្នករំលោភបំពាន និងអ្នកក្លែងបន្លំ។ ការផ្ទេរសិទ្ធិ និងការផ្តល់សិទ្ធិលើម៉ាកអាចដើរតួយ៉ាងសំខាន់ក្នុងការធ្វើពាណិជ្ជកម្មម៉ាកយីហោតាមរយៈភាពជាដៃគូ ការគ្រប់គ្រងរួមគ្នា និងការគំនិតផ្តួចផ្តើមការផ្តល់អាជ្ញាប័ណ្ណពិសេស។

## 1.3. ការការពារម៉ាកយីហោអ្នកក្នុងទីផ្សារនាំចេញ

ការការពារម៉ាករបស់អ្នកនៅក្រៅប្រទេសកម្ពុជាសំដៅលើការទទួលបានសិទ្ធិម៉ាកក្នុងទីផ្សារនាំចេញនីមួយៗ ដែលជាកន្លែងដែលអ្នកចង់ធ្វើពាណិជ្ជកម្មផលិតផល ឬសេវារបស់អ្នក។ សិទ្ធិម៉ាកគឺជាសិទ្ធិនៅក្នុងដែនដី និងមាន សុពលភាពតែក្នុងដែនប្រទេសមួយគត់ (ម៉ាកលក្ខណៈថ្នាក់ជាតិ) ឬក្រុមនៃបណ្តាប្រទេសដែលបានបង្កើតប្រព័ន្ធម៉ាកថ្នាក់តំបន់មួយ (ឧទាហរណ៍ សហភាពអឺរ៉ុប)។ ជាគោលការណ៍ដើម្បីទទួលបានសិទ្ធិម៉ាកនៅបរទេស អ្នកត្រូវដាក់ពាក្យស្នើសុំម៉ាកដាច់ដោយឡែកៗពីគ្នានៅការិយាល័យម៉ាកនៃប្រទេសផ្សេងៗ ដែលអ្នកចង់ឲ្យម៉ាកយីហោរបស់អ្នកត្រូវបានការពារ។ នៅពេលដែលអ្នកទទួលបានសិទ្ធិរបស់អ្នកនៅក្នុងប្រទេសទាំងនោះ អ្នកនឹងត្រូវធ្វើតាមនីតិវិធីដាច់ដោយឡែកនៅការិយាល័យទាំងនោះដើម្បីគ្រប់គ្រងសិទ្ធិរបស់អ្នក(ចុះបញ្ជីម៉ាកសាឡើងវិញ ផ្តល់អាជ្ញាប័ណ្ណ ឬ ផ្ទេរសិទ្ធិ) ។ ទោះជាយ៉ាងណា ជាជនជាតិកម្ពុជា ឬ បុគ្គលដែលមានទីលំនៅដ្ឋាន ឬមានឧស្សាហកម្ម ឬ ការបង្កើតពាណិជ្ជកម្មនៅកម្ពុជា អ្នកអាចទាញយកប្រយោជន៍ពីជម្រើសមួយ ដែលកាន់តែទាក់ទាញ ចំណាយមានប្រសិទ្ធភាព និងមធ្យោបាយងាយស្រួលក្នុងការទទួល និងគ្រប់គ្រងសិទ្ធិម៉ាករបស់អ្នកនៅបរទេស ដោយប្រើប្រាស់ពិធីសារទីក្រុងម៉ាឌ្រីដ ដែលជាសន្ធិសញ្ញាអន្តរជាតិមួយ ដែលកម្ពុជាបានក្លាយជាសមាជិកនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥។

## 2. ពិធីសារទីក្រុងម៉ាឌ្រីដ - ដំណោះស្រាយច្រកតែមួយដើម្បីការពារម៉ាកយីហោរបស់អ្នកនៅបរទេស

ប្រសិនបើអ្នកជាក្រុមហ៊ុន បរិស័ទ សហគ្រាស សហគ្រាសឯកបុគ្គល ឬសហគ្រិនកម្ពុជាផ្សេងៗ អ្នកអាចទាញយកគុណសម្បត្តិពីពិធីសារទីក្រុងម៉ាឌ្រីដ ដើម្បីការពារម៉ាកយីហោរបស់អ្នកនៅច្រើនជាងរាប់រយប្រទេសនៅជុំវិញពិភពលោក តាមរយៈនីតិវិធីសាមញ្ញមួយ និងចំណាយសមស្របសម្រាប់ការដាក់ពាក្យស្នើសុំ និងគ្រប់គ្រងការចុះបញ្ជីម៉ាករបស់អ្នកនៅបរទេស។

### 2.1. សមាជិកសហភាពម៉ាឌ្រីដ ទីផ្សារទាក់ទាញសម្រាប់ការនាំចេញរបស់កម្ពុជា

សហភាពម៉ាឌ្រីដមានសមាជិកចំនួន ១០២ រួមមានរដ្ឋចំនួន ១០០ និងអង្គការអន្តររដ្ឋាភិបាលចំនួនពីរ (សហភាពអឺរ៉ុប និងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក OAPI) ដែលជាភាគីហត្ថលេខីលើពិធីសារទីក្រុងម៉ាឌ្រីដ និងគ្របដណ្តប់លើដែនដីនៃប្រទេសចំនួន ១១៨ ។ ភាគីហត្ថលេខីតំណាងឲ្យជាង ៨០ភាគរយនៃលំហូរពាណិជ្ជកម្មពិភពលោក និងបង្កើតបានជាទីផ្សារទាក់ទាញសម្រាប់ការនាំចេញរបស់កម្ពុជា។

ដៃគូពាណិជ្ជកម្មកំពូលៗរបស់ប្រទេសកម្ពុជាភាគច្រើនគឺសមាជិកសហភាពម៉ាឌ្រីដ។ អ្នកនាំចូលផលិតផលកម្ពុជាកំពូលចំនួន ១៥ មានចំនួនច្រើនជាង ៤ភាគ៥ (៨៣,៣%) នៃការនាំចេញរបស់កម្ពុជានៅឆ្នាំ២០១៦ ក្នុងនោះរួមមានសមាជិកសហភាពម៉ាឌ្រីដចំនួន១៣ ពោលគឺ(តាមលំដាប់នៃតម្លៃនាំចេញ)៖ សហរដ្ឋអាមេរិក អាល្លឺម៉ង់ ចក្រភពអង់គ្លេស ជប៉ុន សិង្ហបុរី ថៃ បារាំង ចិន អេស្ប៉ាញ បែលហ្ស៊ិក អ៊ីតាលី ស្វីស និងហូល្លង់។ សមាជិកសហភាពម៉ាឌ្រីដផ្សេងទៀត ដែលមានតម្លៃខ្ពស់នៃការនាំចេញរបស់ប្រទេសកម្ពុជារួមមាន ប៉ូឡូញ សាធារណរដ្ឋកូរ៉េ វៀតណាម អូស្ត្រាលី សាធារណរដ្ឋឆេក និងសហព័ន្ធរុស្ស៊ី។

**សមាជិកពិធីសារទីក្រុងម៉ាឌ្រីដ**

**សមាជិកចំនួន ១០២ (រួមទាំងសហភាពអឺរ៉ុប និង OAPI)**
**គ្របដណ្តប់ចំនួន ១១៨ ប្រទេស ទិន្នន័យ ខែធ្នូ ឆ្នាំ២០១៨**



## 2.2. ពិធីសារទីក្រុងម៉ាឌ្រីដ និងនីតិវិធីងាយស្រួល

ពិធីសារទីក្រុងម៉ាឌ្រីដត្រូវបានគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ដែលជាទីភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ មានមូលដ្ឋាននៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។ ពិធីសារនេះអនុញ្ញាតឲ្យអ្នកទទួលបាន និងរក្សាការពារម៉ាកយីហោរបស់អ្នកនៅទូទាំងពិភពលោកដោយផ្តល់ជូននូវសំណុំនៃនីតិវិធីដែលមានភាពងាយស្រួល ឆាប់រហ័ស និងចំណាយសមស្របសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងជាចំណុចកណ្តាលក្នុងការគ្រប់គ្រងការចុះបញ្ជីម៉ាកនៅតាមប្រទេសផ្សេងៗទៀត។

### 2.2.1. ការដាក់ពាក្យកណ្តាលដើម្បីស្វែងរកការការពារក្នុងដែនដីផ្សេងៗ

ដោយផ្អែកលើម៉ាកកម្ពុជារបស់អ្នក អ្នកអាចដាក់**ពាក្យស្នើសុំជាអន្តរជាតិ**នៅ DIP ក្នុងការជ្រើសរើសប្រទេសសមាជិកទាំងអស់នៃសហភាពម៉ាឌ្រីដ ដែលអ្នកចង់ឲ្យម៉ាករបស់អ្នកត្រូវបានការពារ។ ពាក្យស្នើសុំអន្តរជាតិត្រូវបានបញ្ជូនបន្តទៅអង្គការ WIPO សម្រាប់ការត្រួតពិនិត្យ ការចុះបញ្ជី និងការបោះពុម្ពផ្សាយ។ នៅពេលដែលម៉ាករបស់អ្នកត្រូវបានកត់ត្រាដោយអង្គការ WIPO នៅក្នុងបញ្ជីអន្តរជាតិ វាត្រូវបានជូនដំណឹងទៅរាល់សមាជិកនៃសហភាពម៉ាឌ្រីដ ដែលត្រូវបានជ្រើសរើស។ សមាជិកទាំងនោះត្រូវសម្រេចចិត្តថាតើពួកគេត្រូវផ្តល់កិច្ចការពារម៉ាករបស់អ្នកនៅក្នុងដែនដីរបស់ពួកគេ ក្នុងរយៈពេលកំណត់យ៉ាងតឹងរឹងបំផុត។ ក្នុងករណីសមាជិកដែលបានជ្រើសរើសមិនបានបញ្ជូនការបដិសេធណាមួយក្នុងរយៈពេលផ្តល់ជូន ចាប់តាំងពីថ្ងៃជូនដំណឹង (ដែលអាចមានរយៈពេល ១២ខែ ឬ១៨ខែ ឬ យូរជាង១៨ខែក្នុងករណីមានការប្តឹងជំទាស់ពីភាគីទីបី) ម៉ាកចុះបញ្ជីអន្តរជាតិត្រូវបានការពារក្នុងដែនដីរបស់សមាជិកនោះ ដូចទៅនឹងការចុះបញ្ជីដោយផ្ទាល់នៅការិយាល័យកម្មសិទ្ធិបញ្ញានៃសមាជិកនោះ។

### 2.2.2. ការគ្រប់គ្រងកណ្តាលសម្រាប់ម៉ាករបស់អ្នក

ពេល**ការចុះបញ្ជីជាអន្តរជាតិ** (IR) របស់អ្នកត្រូវបានទទួល ហើយម៉ាករបស់អ្នកត្រូវបានការពារដោយសមាជិកមួយ ឬ ច្រើននៃសហភាពម៉ាឌ្រីដ ហើយអ្នកនឹងអាចគ្រប់គ្រងសិទ្ធិរបស់អ្នកយ៉ាងងាយស្រួលតាមនីតិវិធីអនឡាញនៅកន្លែងតែមួយ (WIPO) ដើម្បី (១) ចុះបញ្ជីម៉ាករបស់អ្នកសាឡើងវិញរៀងរាល់ ១០ ឆ្នាំម្តង (២) ពង្រីកការការពារដល់ទីផ្សារថ្មីៗនៅពេលវេលាណាមួយ និង (៣) ស្នើសុំការកត់ត្រាកណ្តាលលើប្រភេទនៃការកែប្រែផ្សេងៗនៃការចុះបញ្ជីរបស់អ្នក (ការកត់ត្រាផ្ទេរសិទ្ធិ ការប្តូរឈ្មោះឬអាសយដ្ឋាន ការកំណត់លក្ខខណ្ឌ ការបោះបង់ចោល) ។

## 2.3. គុណសម្បត្តិ តម្លៃត្រូវបានកាត់បន្ថយ ការគ្រប់គ្រងម៉ាកយីហោ និងការធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធភាព

**ការដាក់ពាក្យកណ្តាល**នៃម៉ាករបស់អ្នកក្រោមពិធីសារទីក្រុងម៉ាឌ្រីដផ្តល់នូវគុណសម្បត្តិជាច្រើនដូចជា អ្នកមិនចាំបាច់ដាក់ពាក្យស្នើសុំដោយដាច់ឡែកពីគ្នានៅក្នុងប្រទេសជាច្រើន ព្រាងជាភាសាផ្សេងៗ បង់កម្រៃជារូបិយប័ណ្ណផ្សេងៗ ជួលសេវាអ្នកតំណាងក្នុងស្រុក និងធ្វើតាមនីតិវិធីផ្សេងៗគ្នាតាមប្រទេសទាំងនោះ។ ជំនួសមកវិញ អ្នកអាចដាក់ពាក្យស្នើសុំជាអន្តរជាតិតែមួយនៅ DIP ប្រើប្រាស់ភាសាតែមួយ(ភាសាអង់គ្លេស) បង់កម្រៃជារូបិយប័ណ្ណតែមួយ(ស្វីសហ្វ្រង់) ហើយពាក្យស្នើសុំរបស់អ្នកនឹងមានប្រសិទ្ធភាពនៅរាល់សមាជិករបស់សហភាពម៉ាឌ្រីដ ដែលអ្នកចាប់អារម្មណ៍។ នីតិវិធីនេះមានភាពយ៉ាងសាមញ្ញ ងាយស្រួល ឆាប់រហ័ស និងចំណាយសមស្រប។ អ្នកអាចសន្សំថ្លៃបកប្រែ និងថ្លៃឈ្នួលផ្សេងៗ (អ្នកតំណាងក្នុងស្រុក ការប្តូររូបិយប័ណ្ណ)។ ពេលវេលាកំណត់តឹងរ៉ឹងត្រូវបានកំណត់លើសមាជិកសហភាពម៉ាឌ្រីដ ដើម្បីសម្រេចលើការទទួលស្គាល់សិទ្ធិក្នុងស្រុក ផ្អែកលើការចុះបញ្ជីជាអន្តរជាតិរបស់អ្នក(IR) រួមចំណែកបង្កើនល្បឿននៃនីតិវិធីការការពារគួរឱ្យកត់សម្គាល់។

អត្ថប្រយោជន៍នៃ**ការគ្រប់គ្រងកណ្តាល**គឺមានសារៈសំខាន់ជាងការដាក់ពាក្យស្នើសុំកណ្តាលទាំងនោះដូចជា នៅពេលដែល IR របស់អ្នកត្រូវបានទទួល អ្នកនឹងត្រូវត្រួតពិនិត្យ និងគ្រប់គ្រងកាលបរិច្ឆេទចុះបញ្ជីសាជាថ្មីឡើងវិញ និងនីតិវិធីនៅក្នុងកន្លែងតែមួយ (WIPO) ជំនួសឲ្យកាលបរិច្ឆេទផ្សេងៗជាច្រើន និងនីតិវិធីផ្សេងៗនៅការិយាល័យម៉ាកដាច់ដោយឡែក អ្នកនឹងអាចពង្រីកការការពារម៉ាករបស់អ្នកទៅកាន់ទីផ្សារថ្មីៗ បានយ៉ាងងាយស្រួល(តាមរយៈការជ្រើសរើសប្រទេសបន្ទាប់សម្រាប់ការដាក់ពាក្យ) ហើយអ្នកនឹងអាចធ្វើការផ្លាស់ប្តូរការចុះបញ្ជីម៉ាករបស់អ្នក (ដូចជាការផ្ទេរសិទ្ធិ ការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋានរបស់អ្នកកាន់កាប់ ឬអ្នកតំណាង ការកំណត់លក្ខខណ្ឌ និងការបោះបង់ចោល) ដែលបានកត់ត្រានៅកន្លែងតែមួយ (បញ្ជីអន្តរជាតិដែលត្រូវបានរក្សាទុកដោយ អង្គការ WIPO) និងមានតម្លៃចំណាយទាបបំផុត ។

ការសន្សំចំណាយដែលបានមកពីការប្រើប្រាស់ប្រព័ន្ធម៉ាឌ្រីដមានសារៈសំខាន់ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម(SMEs) ។ ៨០ភាគរយនៃអ្នកប្រើប្រាស់ប្រព័ន្ធម៉ាឌ្រីដដែលជាប្រភេទ សហគ្រាសធុនតូច និងមធ្យម នឹងមានប្រព័ន្ធប្រវត្តិឯកសារមួយសម្រាប់ IRs មួយ ឬពីរ។

ទោះជាយ៉ាងណាក៏ដោយ **គុណសម្បត្តិ** នៃពិធីសារទីក្រុងម៉ាឌ្រីដ មិនត្រឹមតែកាត់បន្ថយចំណាយ និងពន្លឿននីតិវិធី ដែលបានមកការដាក់ពាក្យកណ្តាល និងការគ្រប់គ្រងកណ្តាលនៃ IR ទេ។ ពិធីសារក៏ផ្តល់ជូនអ្នកមុនពេលដែលម៉ាកយីហោមានវត្តមាននៅបរទេស ព្រោះវាជាមធ្យោបាយដើម្បីចាប់យកកេរ្តិ៍ឈ្មោះអន្តរជាតិយ៉ាងឆាប់រហ័ស និងបង្កើតនូវតម្លៃម៉ាករបស់អ្នកនៅទូទាំងពិភពលោក។ ចេញពីទស្សនៈជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ការទទួលបានវត្តមានម៉ាកយីហោលឿននៅកម្រិតពិភពលោកផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចបន្ថែមទៀត រួមទាំងការបង្កើន ឱកាសកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ និងលទ្ធភាពធ្វើជាដៃគូជាមួយសហគ្រិនអន្តរជាតិ ដើម្បីបង្កើនប្រសិទ្ធភាពការអភិវឌ្ឍន៍វដ្តជីវិតនិងរួមបញ្ចូលសង្វាក់ផ្គត់ផ្គង់ជាសកល។

## ហេតុអ្វីបានជាប្រើពិធីសារទីក្រុងម៉ាឌ្រីដ?

### កាត់បន្ថយតម្លៃ និងពន្លឿននីតិវិធីដើម្បីការពារម៉ាករបស់អ្នក

- ពាក្យស្នើសុំតែមួយ (នៅ DIP)
- ភាសាតែមួយ (អង់គ្លេស)
- រូបិយប័ណ្ណតែមួយប្រភេទសម្រាប់ការបង់កម្រៃ (CHF)
- មិនចាំបាច់ត្រូវការអ្នកតំណាងច្រើន
- ចុះបញ្ជីសារឡើងវិញតែមួយ កាលបរិច្ឆេទតែមួយ និងការស្នើសុំតែមួយ
- នីតិវិធីសម្រាប់ការកែប្រែតែមួយ
- លទ្ធភាពពង្រីកការការពារដល់បណ្តាប្រទេសផ្សេងៗនៅគ្រប់ពេលវេលា

### ម្ចាស់ម៉ាកទទួលបាន

- ម៉ាកនៅបរទេស
- កេរ្តិ៍ឈ្មោះម៉ាកយីហោជាអន្តរជាតិ និងជាទ្រព្យអរូបិយ
- ការផ្តល់អាជ្ញាប័ណ្ណ និងឱកាសភាពជាដៃគូ

## 3. ការជ្រើសរើសម៉ាករបស់អ្នក ការអនុវត្តល្អៗ

ការបង្កើតម៉ាកយីហោ សំដៅយកការជ្រើសរើសយកសញ្ញា (ម៉ាក) ដែលនឹងញែកផលិតផល ឬសេវារបស់អ្នកពីដៃគូប្រកួតប្រជែងរបស់អ្នក។

ជាគោលការណ៍ សញ្ញាណាដែលមានសមត្ថភាពញែកទំនិញ ឬសេវារបស់អ្នកពីអ្នកដទៃក្នុងទីផ្សារ អាចបង្កើតជាម៉ាកបាន។ ដូច្នេះ ម៉ាករបស់អ្នកអាចត្រូវបានបង្កើតឡើងដោយ និមិត្តសញ្ញាមួយ ការរចនាមួយ ពាក្យមួយ ពណ៌មួយ សញ្ញាណាមួយផ្សេងទៀត ឬការរួមបញ្ចូលគ្នា។ ទោះជាយ៉ាងណាក៏ដោយ នៅពេលជ្រើសរើសយកម៉ាករបស់អ្នក មានតម្រូវការ ឬដែនកំណត់ជាក់លាក់ដែលអ្នកត្រូវពិចារណា។

- ម៉ាករបស់អ្នកត្រូវតែមានលក្ខណៈញែកដាច់ មានន័យថាវាគួរតែមានសញ្ញាដែលបម្រើឲ្យការកំណត់ផលិតផល ឬ សេវារបស់អ្នក និងដើម្បីសម្គាល់លក្ខណៈខុសពីរបស់អ្នកដទៃ។ គំនូរធរណីមាត្រទូទៅ (ឧទាហរណ៍ ចតុកោណកែងមួយ រង្វង់មួយ ការេមួយ) សញ្ញាទូទៅ (ឧទាហរណ៍ អក្សរធម្មតា ឬលេខចាប់ពីរខ្ទង់) នាមត្រកូលទូទៅ និងឈ្មោះកន្លែងល្បីៗ ត្រូវបានគេចាត់ទុកថាជាសញ្ញាគ្មានលក្ខណៈញែកដាច់។
- ម៉ាករបស់អ្នកមិនគួរមានលក្ខណៈលើកសរសើរ (ឧទាហរណ៍ "ល្អបំផុត" "ល្អឥតខ្ចោះ") ឬ ពិពណ៌នាពីទំនិញ ឬសេវាជាក់លាក់ណាមួយ ដែលអ្នកចង់ធ្វើពាណិជ្ជកម្ម (ឧទាហរណ៍ "ផ្លែប៉ោម" សម្រាប់ផ្លែប៉ោម ឬ "ឱសថ" សម្រាប់ការលក់ផលិតផលឱសថ) ដែលនេះអាចនាំឲ្យមានការបដិសេធការចុះបញ្ជី។
- ម៉ាករបស់អ្នកគួរមានលក្ខណៈជារូបភាពតំណាង ដែលការិយាល័យម៉ាកភាគច្រើនតម្រូវឲ្យក្រាហ្វិកជារូបភាពតំណាង ឬ ម៉ាក (ឧទា វាគួរតែមានសមត្ថភាពក្នុងការផលិតសារឡើងវិញនៅលើក្រដាស) ។ ការិយាល័យមួយចំនួនទទួលយកមធ្យោបាយផ្សេងទៀតនៃការបង្ហាញសម្រាប់ប្រភេទពិសេសនៃម៉ាក (ឧទាហរណ៍ ការថតសម្លេង MP3 សម្រាប់ម៉ាកជាសំឡេង) ។ ទោះជាយ៉ាងណា ប្រព័ន្ធម៉ាឌ្រីដនៅតែតម្រូវឲ្យម៉ាករបស់អ្នកត្រូវមានរូបភាពតំណាងជាក្រាហ្វិក។
- ម៉ាករបស់អ្នកមិនគួរជាមុខងារ ដែលមានន័យថាសញ្ញាដែលបង្កើតម៉ាករបស់អ្នកមិនមានចរិតលក្ខណៈផ្តាច់មុខចេញពីប្រភេទទំនិញនោះ ឬដែលគឺទទួលបានពីលទ្ធផលបច្ចេកទេសចាំបាច់។ នេះគឺជាករណីពិសេសពាក់ព័ន្ធនឹងម៉ាកដែលមានវិមាត្របីជ្រុង។
- ម៉ាករបស់អ្នកមិនគួរមានលក្ខណៈបោកបញ្ឆោត។ សញ្ញាមួយដែលបង្ហាញពីប្រភពដើមមិនពិតប្រាកដ ឬ ចរិតលក្ខណៈមិនពិតប្រាកដនៃផលិតផល ដែលអាចត្រូវបានបដិសេធការពារក្នុងមូលដ្ឋានបោកបញ្ឆោត។
- សញ្ញាដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ សីលធម៌ (ឧទាហរណ៍ ការធ្វើឲ្យប៉ះពាល់ដល់មនោសញ្ចេតនាបែបសាសនាចំពោះបញ្ហាសាធារណៈ ឬមានបញ្ហាអាសអាភាស) អាចត្រូវបានដកចេញពីការការពារជាម៉ាក ។
- ទង់ជាតិរដ្ឋ និមិត្តរូបរដ្ឋ និង ឈ្មោះ និងនិមិត្តរូបរបស់អង្គការអន្តរដ្ឋាភិបាលត្រូវបានដកចេញពីការការពារជាម៉ាកនៅប្រទេសភាគច្រើននៅជុំវិញពិភពលោក។
- ជាចុងក្រោយ និងសំខាន់បំផុតដែលអ្នកត្រូវប្រាកដថា សញ្ញាដែលអ្នកចង់ប្រើជាម៉ាករបស់អ្នកនៅមិនត្រូវបានប្រើប្រាស់ក្នុងទីផ្សារ និងវាមិនដូចគ្នា ឬស្រដៀងគ្នានឹងម៉ាកល្បី ឬម៉ាកដែលបានចុះឈ្មោះរួច ឬ បានដាក់ពាក្យស្នើសុំចុះបញ្ជីដោយនរណាម្នាក់ផ្សេងទៀត សម្រាប់ទំនិញ ឬ សេវាដូចគ្នា។ អាស្រ័យហេតុនេះ វាមានសារៈសំខាន់ណាស់ដែលអ្នកធ្វើការស្រាវជ្រាវឲ្យពេញទំហឹងសម្រាប់អាចយកមកប្រើប្រាស់បាននៃម៉ាករបស់អ្នកក្នុងទីផ្សារទាំងនោះ ដែលជាកន្លែងដែលអ្នកចង់ត្រូវបានការការពារម៉ាក។

**គន្លឹះ**

- *ជ្រើសរើសម៉ាករបស់អ្នកដោយប្រុងប្រយ័ត្ន*
- *ត្រូវប្រាកដថាមិនត្រូវហាមឃាត់ដោយច្បាប់*
- *ពិនិត្យមើលថាវាមិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់ផ្សេងទៀត (ស្រាវជ្រាវនៅក្នុងស្រុក និងបរទេស)*

## 3.1. ការស្រាវជ្រាវម៉ាកក្នុងប្រទេសកម្ពុជា

មុននឹងដាក់ពាក្យស្នើសុំជាតិនៅ DIP ដើម្បីទទួលបានការការពារម៉ាករបស់អ្នកនៅក្នុងប្រទេសកម្ពុជា អ្នកគួរតែប្រាកដថាសញ្ញាដែលអ្នកកំពុងគ្រោងប្រើជាម៉ាកនៅកម្ពុជាមិនត្រូវ បានដកចេញពីការការពារដោយច្បាប់ម៉ាកទេ (https://www.wipo.int/wipolex/en/details.jsp?id=5780; www.facebook.com/cambodiaip.gov.kh) ។

អ្នកគួរតែពិនិត្យមើលថា តើសញ្ញានោះមិនទាន់ត្រូវបានដាក់ពាក្យស្នើសុំ ឬចុះបញ្ជីជាម៉ាក សម្រាប់ទំនិញឬសេវាដូចគ្នាដោយនរណាម្នាក់ផ្សេងទៀតទេ។ អ្នកអាចធ្វើដូច្នេះបានដោយទាញយកព័ត៌មានតាមមធ្យោបាយស្រាវជ្រាវម៉ាកនៅ DIP តាមរយៈគេហទំព័រ www.cambodiaip.gov.kh/tmsearch ឬ www.wipo.int/branddb/kh/en ។

## 3.2. ការស្រាវជ្រាវសម្រាប់ម៉ាកនៅបរទេស ប្រព័ន្ធទិន្នន័យអនឡាញ (ASEAN TMVIEW, TMVIEW, GLOBAL BRANDS)

មុននឹងដាក់ពាក្យស្នើសុំជាអន្តរជាតិ ដើម្បីការពារម៉ាករបស់អ្នកនៅបរទេស អ្នកគួរតែពិនិត្យមើលថាតើសញ្ញាដែលអ្នកកំពុងគ្រោងនឹងប្រើជាម៉ាករបស់អ្នកនៅក្នុងទីផ្សារនាំចេញមិនមែនជារបស់អ្នកផ្សេងទៀតនៅទីនោះទេ។ នេះមានន័យថាការស្រាវជ្រាវម៉ាកដែលមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា ដែលបានការពាររួចហើយនៅក្នុងទីផ្សារទាំងនោះសម្រាប់ទំនិញ ឬសេវាដូចគ្នា។ ការិយាល័យម៉ាកមួយចំនួនរបស់សមាជិកសហភាពម៉ាឌ្រីដផ្តល់លទ្ធភាពឲ្យធ្វើការស្រាវជ្រាវតាមប្រព័ន្ធទិន្នន័យម៉ាករបស់ពួកគេនៅលើបណ្តាញគេហទំព័រផ្ទាល់ខ្លួនរបស់ពួកគេ។ ទោះជាយ៉ាងនេះក្តីមធ្យោបាយដ៏ល្អបំផុតដើម្បីចាប់ផ្តើមស្រាវជ្រាវម៉ាកស្រដៀងគ្នាគឺត្រូវរកព័ត៌មានជាមួយ TMview និង ASEAN TMview ។

TMview (https://www.tmdn.org/tmview/welcome) គឺទម្រង់ប្រព័ន្ធព័ត៌មានម៉ាកមួយដែលបង្កើតឡើងដោយការិយាល័យម៉ាកចំនួន ៦២ ជុំវិញពិភពលោក (ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ) ដែលមានគោលបំណងដើម្បីធ្វើឲ្យទិន្នន័យម៉ាកអាចប្រើបានទូលំទូលាយ និងងាយស្រួលដល់សាធារណជន និងដោយមិនគិតថ្លៃ។ ASEAN TMview (http://www.asean-tmview.org/tmview/welcome) គឺជាប្រព័ន្ធទិន្នន័យស្រដៀងគ្នា ដែលបង្កើតឡើងដោយប្រទេសសមាជិកអាស៊ានចំនួន៩ ដោយមានការសហការពី TMview ។ TMview និង ASEAN TMview ផ្តល់នូវលទ្ធភាពដើម្បីស្វែងរកពីស្ថានភាពម៉ាករួមនៅក្នុងប្រទេសចំនួន ៨២ (រួមមានបណ្តាប្រទេសចំនួន ១៥នៅទ្វីបអាស៊ី ៣៦នៅទ្វីបអឺរ៉ុប ២១នៅទ្វីបអាហ្វ្រិកនិង ១០នៅទ្វីបអាមេរិក)។ ទម្រង់ប្រព័ន្ធទាំងនេះផ្តល់នូវការទទួលបានព័ត៌មានអំពីពាក្យស្នើសុំ និងការចុះបញ្ជីម៉ាកចំនួនជាង ៥១,៩ លានដែលមានសុពលភាពនៅក្នុងប្រទេសទាំងនោះ បន្ថែមការចុះបញ្ជីជាអន្តរជាតិនៅក្រោមប្រព័ន្ធម៉ាឌ្រីដ រួមមានទិន្នន័យទាក់ទងនឹងឈ្មោះម៉ាក ឈ្មោះអ្នកដាក់ពាក្យ ប្រភេទម៉ាក ក្រាហ្វិកជារូភាពតំណាង ស្ថានភាពផ្លូវច្បាប់ យថាប្រភេទទំនិញនិងសេវា កូដជំពូក។ល។ TMview និង ASEAN TMview អនុញ្ញាតឲ្យអ្នកធ្វើការស្រាវជ្រាវរកម៉ាក ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ តាមមធ្យោបាយយ៉ាងងាយស្រួល។ ភាពត្រឹមត្រូវនៃទិន្នន័យបង្ហាញនៅក្នុងប្រព័ន្ធទិន្នន័យទាំងនោះ គឺជាការទទួលខុសត្រូវផ្តាច់មុខរបស់ការិយាល័យម៉ាកដែលផ្តល់ជូន។ ចាប់តាំងពីការណែនាំរបស់ខ្លួននៅខែមេសាឆ្នាំ ២០១០ និងរហូតដល់ខែកក្កដាឆ្នាំ ២០១៨ TMview បានបម្រើឲ្យការស្រាវជ្រាវរកជាង៤៩លាន ពី១៦៦ ប្រទេសផ្សេងគ្នា។

ដើម្បីស្វែងរកស្ថានភាពទូទៅម៉ាកបរទេស អ្នកក៏អាចរកព័ត៌មានជាមួយប្រព័ន្ធទិន្នន័យម៉ាកយីហោសកល Global Brand Database (http://www.wipo.int/branddb/en/index.jsp) ដែលជាច្រកអេឡិចត្រូនិកគ្រប់គ្រងដោយ អង្គការWIPO មានផ្ទុកការកត់ត្រាជាង ៣៦លាន ពី៤០ប្រទេស និងការប្រមូលជាអន្តរជាតិ រួមទាំងទិន្នន័យពីម៉ាក ការហៅឈ្មោះតាមប្រភពដើម និងសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបជាតិផ្សេងទៀតដែលត្រូវបានការពារនៅក្នុងប្រទេសផ្សេងៗជុំវិញពិភពលោក ក៏ដូចជាឈ្មោះអក្សរកាត់ និងនិមិត្តរូបរបស់អង្គការអន្តររដ្ឋាភិបាល។

## 4. ការរៀបចំ និងដាក់ពាក្យស្នើសុំម៉ាកជាអន្តរជាតិ ការអនុវត្តល្អៗ

នៅពេលអ្នកបានជ្រើសរើសម៉ាករបស់អ្នកសម្រាប់ការការពារនៅបរទេស អ្នកត្រូវត្រៀមជាស្រេចដើម្បីរៀបចំ និងដាក់ពាក្យស្នើសុំអន្តរជាតិរបស់អ្នក។

**ការដាក់ពាក្យកណ្តាលនៃពាក្យស្នើសុំជាអន្តរជាតិ**




### 4.1. សេចក្តីតម្រូវ ការទទួលសិទ្ធិ ម៉ាកគោលក្នុងប្រទេសកម្ពុជា

DIP អនុវត្តពាក្យស្នើសុំជាអន្តរជាតិនៃពិធីសារទីក្រុងម៉ាឌ្រីដផ្តើមចេញពីប្រទេសកម្ពុជា។ អ្នកមានសិទ្ធិដាក់ពាក្យស្នើសុំជា អន្តរជាតិនៅ DIP ប្រសិនបើ: (១)អ្នកជាជនជាតិខ្មែរ ឬអ្នកជារូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានទីតាំងនៅក្នុងប្រទេស កម្ពុជា ឬអ្នកមានគ្រឹះស្ថានឧស្សាហកម្ម ឬការបង្កើតពាណិជ្ជកម្មពិតប្រាកដ និងកំពុងប្រតិបត្តិនៅប្រទេសកម្ពុជា និង (២) អ្នកមាន "ម៉ាកគោល" នៅប្រទេសកម្ពុជា ដែលមានន័យថាម៉ាករបស់អ្នកត្រូវបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំសម្រាប់ការពារថ្នាក់ជាតិនៅរួចហើយនៅ DIP ។

### 4.2. ការដាក់ពាក្យស្នើសុំជាអន្តរជាតិនៅ DIP

ប្រសិនបើអ្នកចង់ដាក់ពាក្យស្នើសុំជាអន្តរជាតិនៃពិធីសារទីក្រុងម៉ាឌ្រីដនៅ DIP អ្នកត្រូវតែបំពេញសំណុំបែបបទពិសេសមួយ (MM2) ជាភាសាអង់គ្លេស ដែលអ្នកអាចទាញយកពីគេហទំព័ររបស់ អង្គការ WIPO (http://www.wipo.int/madrid/en/forms/) ។ នៅពេលអ្នកបានបំពេញសំណុំបែបបទដាក់ពាក្យស្នើសុំជាអន្តរជាតិ MM2 អ្នកត្រូវតែដាក់ពាក្យសុំនៅ DIP និងបង់កម្រៃការបញ្ជាក់ការដាក់ពាក្យស្នើសុំទៅតាមជំពូក។

### 4.3. មាតិកានៃពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក បទបញ្ជា ឬតាមជម្រើស

ពាក្យស្នើសុំអន្តរជាតិរបស់អ្នក(MM2) ត្រូវតែមាន: (១)ឈ្មោះ និងអាសយដ្ឋានរបស់អ្នក (២)គំរូម៉ាករបស់អ្នក ដែលត្រូវតែដូចគ្នាទៅនឹងម៉ាកគោលរបស់អ្នកនៅក្នុងប្រទេសកម្ពុជា (៣)យថាប្រភេទទំនិញ និងសេវាសម្រាប់ការពារ ដែលត្រូវតែមានដូចការបង្ហាញក្នុងម៉ាកគោលរបស់អ្នក និង (៤) បញ្ជីសមាជិកសហភាពម៉ាឌ្រីដ សម្រាប់ស្វែងរកការការពារម៉ាក (ប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើស ឬ DCPs) ។ សេចក្តីតម្រូវទាំងនេះគឺចាំបាច់ និងមានឥទ្ធិពលលើកាលបរិច្ឆេទនៃពាក្យស្នើសុំជាអន្តរជាតិ។

ពាក្យស្នើសុំជាអន្តរជាតិ(MM2) ត្រូវតែមានផងដែរនូវ (១) ការបញ្ជាក់ពីសិទ្ធិរបស់អ្នកក្នុងការដាក់ពាក្យស្នើសុំ (ការបង្កើតពាណិជ្ជកម្ម ឬស្នាក់នៅក្នុងប្រទេសកម្ពុជា ឬសញ្ជាតិខ្មែរ) (២)ពាក្យសុំសិទ្ធិជាអាទិភាពប្រសិនបើមាន (៣) ឈ្មោះនិងអាសយដ្ឋានរបស់អ្នកតំណាង ប្រសិនបើត្រូវបានតែងតាំង (៤) លេខដាក់ពាក្យ និងកាលបរិច្ឆេទម៉ាកគោលរបស់អ្នកនៅប្រទេសកម្ពុជា (៥)ការបង្ហាញអំពីម៉ាក (ប្រភេទម៉ាក ពណ៌ប្រសិនបើមាន) (៦) ការពិពណ៌នាពីម៉ាក បើតម្រូវដោយ DIP[1] (៧)សំឡេងអានរបស់ម៉ាក ប្រសិនបើមាន (៨)ចំនួនទឹកប្រាក់ដែលត្រូវបង់ និងមធ្យោបាយបង់ប្រាក់។

ខ្លឹមសារបន្ថែមមួយចំនួន (ឧទាហរណ៍ ការប្រកាសពីបំណងប្រើប្រាស់ម៉ាក) អាចត្រូវបានទាមទារនៅពេលដែលសមាជិកសហភាពម៉ាឌ្រីដណាមួយត្រូវបានជ្រើសរើសក្នុងពាក្យស្នើសុំ (សូមមើលផ្នែក 4.5 ខាងក្រោម) ។

ពាក្យស្នើសុំជាអន្តរជាតិក៏អាចមាន (មាតិកាជ្រើសរើស)ដូចជា (១) ការបញ្ជាក់ពីសញ្ជាតិរបស់អ្នក ឬប្រសិនបើជានីតិបុគ្គល លក្ខណៈច្បាប់របស់អ្នកនិងច្បាប់ជាតិដែលត្រូវបានបង្កើតឡើងជានីតិបុគ្គល (២)ការបកប្រែនៃម៉ាក (៣) ការពិពណ៌នាដោយស្ម័គ្រចិត្តអំពីម៉ាក (៤)ការបញ្ជាក់ពីពាក្យដែលជានៃផ្នែកសំខាន់របស់ម៉ាកដែលជាពណ៌ នៅពេលពណ៌ត្រូវបានទាមទារឲ្យការពារ និង (៥)ការសុំបដិសេធមិនការពារ។

សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបបំពេញសំណុំបែបបទដាក់ពាក្យស្នើសុំអន្តរជាតិរបស់អ្នក (MM2) អ្នកអាចយកព័ត៌មានជាមួយឯកសារ PDF "ការអនុវត្តច្រើនបំផុតនៃប្រព័ន្ធម៉ាឌ្រីដដូចជា ព័ត៌មាន និងការណែនាំអនុវត្តអំពីរបៀបប្រើសំណុំបែបបទ" ដែលអ្នកអាចទាញយកពី http://www.wipo.int/madrid/en/forms/ ឬសៀវភៅមគ្គុទ្ទេសក៏អង្គការ WIPO ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិទំព័រ B.II.7 ដល់B.II.20តាមអាសយដ្ឋានដូចខាងក្រោម http: //www.wipo.int/madrid/en/guide/។

**គន្លឹះ**

*មុនពេលដាក់ពាក្យស្នើសុំ IA របស់អ្នក សូមពិនិត្យ "ធ្វើការពិនិត្យឲ្យបានច្រើនបំផុតលើប្រព័ន្ធម៉ាឌ្រីដ: ព័ត៌មាន និងគន្លឹះអនុវត្តលើរបៀបប្រើប្រាស់ទម្រង់ដ៏ត្រឹមត្រូវ" តាមរយៈគេហទំព័រ*
*http://www.wipo.int/madrid/en/forms/*

## 4.4. ការទាញយកបញ្ជីទំនិញ និងសេវារបស់អ្នក ការប្រើឧបករណ៍ចាត់ចំណាត់ថ្នាក់ (TMCLASS, ASEAN TMCLASS, MGS)

TMclass

asean TMclass

នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមួយ (ជាតិ ឬក៏ដូចអន្តរជាតិ) អ្នកត្រូវបង្ហាញឲ្យបានត្រឹមត្រូវពីទំនិញ និងសេវាដែលសម្រាប់ស្វែងរកការការពារម៉ាក (ពាក្យដែលទូលំទូលាយពេក ភាសាមិនត្រឹមត្រូវ ឬមិនអាចយល់ គឺមិនត្រូវបានទទួលយកទេ) ហើយទំនិញ និងសេវាទាំងនោះត្រូវបានចាត់ថ្នាក់ឲ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាសម្រាប់គោលបំណងនៃការចុះញ្ជីម៉ាក(ចំណាត់ថ្នាក់ទីក្រុងនីស NICE) ។ ចំណងជើងជំពូកមិនត្រូវបានទទួលយកសម្រាប់ការចុះបញ្ជីនៅប្រទេសកម្ពុជានោះទេ។

ដើម្បីឲ្យប្រាកដថាបញ្ជីទំនិញ និងសេវារបស់អ្នកអនុលោមទៅតាមតម្រូវការចាំបាច់ ដែលអាចទទួលយកបានទាំងនៅកម្រិតជាតិ និងអន្តរជាតិ វាគឺជាការផ្តល់អនុសាសន៍ដ៏ល្អដែលអ្នកត្រូវយកព័ត៌មានពី TMclass (http://euipo.europa.eu/ec2/) និង ASEAN TMclass (http://www.asean-tmclass.org/ec2/) ។ ទាំងនោះ គឺជាឧបករណ៍ស្រាវជ្រាវ និងធ្វើចាត់ចំណាត់ថ្នាក់ទំនិញ និងសេវាតាមអនឡាញដោយឥតគិតថ្លៃ ហើយអនុញ្ញាតឲ្យអ្នកជ្រើសរើសមុខទំនិញ និងសេវាដែលបានទទួលយក និងចាត់ចំណាត់ថ្នាក់យ៉ាងត្រឹមត្រូវដោយការិយាល័យម៉ាកចំនួន ៧៣ (ថ្នាក់ជាតិ តំបន់ អន្តរជាតិ) ពីជុំវិញពិភពលោក។ ការិយាល័យដែលចូលរួមក្នុង TMclass រួមមានសហភាពអឺរ៉ុប ចិន ជប៉ុន អាមេរិក និងប្រទេសជាច្រើនទៀត។ ការិយាល័យអាស៊ានទាំងអស់ចូលរួមក្នុង ASEAN TMclass ។

[1] *ប្រសិនបើម៉ាកផ្គុំឡើង ឬមានបញ្ហាតួអក្សរដែលមិនជាអក្សរឡាតាំង ឬលេខក្រៅពីឡាតាំងផ្សេងពីលេខអារ៉ាប់ ការសំឡេងអានជាអក្សរឡាតាំងឬលេខអារ៉ាប់ត្រូវតែផ្តល់ជូន។*

ហើយនៅពេលរៀបចំពាក្យស្នើសុំម៉ាកថ្នាក់ជាតិរបស់អ្នកនៅប្រទេសកម្ពុជាដែលនឹងត្រូវប្រើជាមូលដ្ឋាន (ម៉ាកគោល) សម្រាប់ពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក វាមានអត្ថប្រយោជន៍ដើម្បីយកព័ត៌មានពី TMclass និង ASEAN TMclass ។ ប្រព័ន្ធទិន្នន័យទាំងនោះនឹងជួយអ្នកព្រាងបញ្ជីទំនិញ និងសេវារបស់អ្នកសម្រាប់ពាក្យស្នើសុំទាំងពីរនេះ។ អ្នកគួរគិតថា ទំនិញ និងសេវានៅក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក គួរតែត្រូវបានគ្របដណ្តប់ដោយការបញ្ជាក់ដូចក្នុងម៉ាកគោលរបស់អ្នក។

នៅពេលរៀបចំពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក អ្នកប្រហែលជាអាចមានយកព័ត៌មានពីប្រព័ន្ធគ្រប់គ្រងមុខទំនិញ និងសេវា (MGS) (https://webaccess.wipo.int/mgs/) ដែលជាឧបករណ៍អនឡាញឥតគិតថ្លៃផ្តល់ដោយ អង្គការ WIPO ដែលជួយអ្នកចងក្រងបញ្ជីទំនិញ និងសេវា ដែលអ្នកត្រូវការដាក់ពាក្យស្នើសុំនៅពេលដាក់ពាក្យស្នើសុំជាអន្តរជាតិ។ MGS ផ្តល់ឲ្យអ្នកនូវលទ្ធភាពទទួលបាននូវមុខទំនិញ និងសេវាមាត្រដ្ឋានជាង ៩៤ពាន់ ជាភាសាអង់គ្លេស ដែលត្រូវបានធ្វើចាត់ថ្នាក់យ៉ាងត្រឹមត្រូវដោយអង្គការ WIPO យោងតាមចំណាត់ថ្នាក់ចុងក្រោយនៃចំណាត់ថ្នាក់អន្តរជាតិ (Nice Classification) និងទទួលយកដោយអង្គការ WIPO ក្រោមនីតិវិធីនៃប្រព័ន្ធម៉ាឌ្រីដ។ លើសពីនេះទៅទៀត វាអនុញ្ញាតឲ្យអ្នកពិនិត្យមើលថាតើមុខទំនិញ និងសេវាដែលអ្នកគ្រោងនឹងដាក់ត្រូវបានទទួលយកដោយការិយាល័យនៃសមាជិក ៣៥ នៃសហភាពម៉ាឌ្រីដ រួមមានប្រទេសចិន សហរដ្ឋអាមេរិក សហភាពអឺរ៉ុប។ល។

## 4.5. ការជ្រើសរើសយកដែនដីដែលជាកន្លែងទទួលបានការការពារ

ក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក អ្នកត្រូវតែជ្រើសរើសក្នុងចំណោមសមាជិកសហភាពម៉ាឌ្រីដទាំងអស់ (ប្រទេសហត្ថលេខីរបស់ពិធីសារទីក្រុងម៉ាឌ្រីដ) ដែលអ្នកចង់ឲ្យម៉ាករបស់អ្នកត្រូវបានការពារ។ ដោយគូសយកប្រអប់នៅជាប់ឈ្មោះសមាជិកនីមួយៗក្នុងពាក្យស្នើសុំ (MM២) ដែលអ្នកអាចជ្រើសរើសសមាជិកសហភាពម៉ាឌ្រីដណាមួយ លើកលែងប្រទេសកម្ពុជា។ ម៉ាករបស់អ្នកនៅកម្ពុជា (ម៉ាកគោល) នឹងបន្តបានការការពារក្រោមច្បាប់កម្ពុជាដែលត្រូវបានចុះបញ្ជីដោយ DIP ។

នាពេលបច្ចុប្បន្ននេះ(ខែធ្នូ ២០១៨) អ្នកអាចជ្រើសរើសបានរហូតដល់ ១០១ ប្រទេសហត្ថលេខីរបស់ពិធីសាម៉ាឌ្រីដ រួមមាន ៩៩ ប្រទេស និងអង្គការអន្តររដ្ឋាភិបាលពីរគឺ សហភាពអឺរ៉ុប និងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក (OAPI) ។ តាមរយៈការជ្រើសរើសយកសហភាពអឺរ៉ុប អ្នកអាចទទួលបានការការពារម៉ាករបស់អ្នកនៅក្នុងប្រទេសជាសមាជិកចំនួន ២៨។ ដោយការជ្រើសរើសយក OAPI អ្នកអាចទទួលបានការការពារម៉ាករបស់អ្នកនៅក្នុងប្រទេសជាសមាជិកចំនួន ១៧ ។

ប្រទេសហត្ថលេខីមួយចំនួន មានតម្រូវការពិសេសដែលអ្នកត្រូវពិចារណាពេលដែលជ្រើសរើសយកក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក។ ប្រសិនបើអ្នកជ្រើសរើសយកសហភាពអឺរ៉ុប (កូដ EM នៅក្នុងសំណុំបែបបទ MM២) អ្នកត្រូវតែបង្ហាញភាសាការងារទីពីរសម្រាប់នីតិវិធីនៅ EUIPO នៅក្នុងសំណុំបែបបទ (MM២) ហើយអ្នកត្រូវតែភ្ជាប់ពាក្យសុំបន្ថែមសំណុំបែបបទ(MM១៧) ប្រសិនបើអ្នកចង់ទាមទារសិទ្ធិអាទិភាពនៅសហភាពអឺរ៉ុប (សម្រាប់ព័ត៌មានលម្អិត សូមមើលផ្នែកទី 6.2 ស្តីពីការទទួលបានការការពារនៅសហភាពអឺរ៉ុបខាងក្រោម) ។

ប្រសិនបើអ្នកជ្រើសរើសយកសហរដ្ឋអាមេរិក(US) អ្នកត្រូវតែភ្ជាប់ពាក្យស្នើសុំបន្ថែមសំណុំបែបបទ(MM១៨) ទៅនឹងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក(MM2) ដោយប្រកាសពីបំណងដើម្បីប្រើម៉ាកនេះនៅសហរដ្ឋអាមេរិក។ លើសពីនេះទៀត ប្រសិនបើអ្នកជារូបវន្តបុគ្គល អ្នកគួរតែបង្ហាញសញ្ជាតិរបស់អ្នកនៅក្នុងពាក្យស្នើសុំអន្តរជាតិសំណុំបែបបទ (MM២) ហើយបើអ្នកជានីតិបុគ្គល អ្នកគួរតែបញ្ជាក់ពីប្រភេទច្បាប់និងប្រទេសក្រោមច្បាប់ដែលអ្នកត្រូវបានរៀបចំជានីតិបុគ្គលនោះ។

ជាចុងក្រោយ ប្រសិនបើអ្នកជ្រើសរើសយកប្រទេសប្រ៊ុយណេ ឥណ្ឌា អៀរឡង់ ឡេសូតូ ម៉ូហ្សំប៊ិក ញូវហ្សេលែន សិង្ហបុរី ឬចក្រភពអង់គ្លេស ដោយគ្រាន់តែគូសប្រអប់ដែលនៅជិតឈ្មោះប្រទេសក្នុងពាក្យស្នើសុំជាអន្តរជាតិសំណុំបែបបទ(MM២) អ្នកក៏កំពុងប្រកាសពីបំណងដើម្បីប្រើម៉ាកនៅប្រទេសទាំងនោះផងដែរ។

ARISE+
ASEAN Intellectual Property Rights

## ពិធីសារទីក្រុងម៉ាឌ្រីដ

**គោលដៅដាក់ពាក្យទៅកម្ពុជាច្រើនជាងគេ (ខែធ្នូ ឆ្នាំ២០១៨)**
(# **ការជ្រើសរើសក្នុងពាក្យស្នើសុំជាអន្តរជាតិ** + **ការជ្រើសរើស បន្តបន្ទាប់បន្ថែម**)

| ភាគីហត្ថលេខី | # ការជ្រើសរើស (IA+SD) | ភាគីហត្ថលេខី | # ការជ្រើសរើស (IA+SD) |
|---|---|---|---|
| ចិន | 7 | បារាំង | 1 |
| ថៃ | 5 | ឥណ្ឌា | 1 |
| វៀតណាម | 5 | ឥណ្ឌូនេស៊ី | 1 |
| ឡាវ | 2 | កេនយ៉ា | 1 |
| ណូវែលសេឡង់ | 2 | OAPI | 1 |
| សិង្ហបុរី | 2 | ហ្វីលិពីន | 1 |
| អាមេរិក | 2 | សហព័ន្ធរុស្ស៊ី | 1 |
| អូស្ត្រាលី | 1 | ស្វីស | 1 |
| ព្រុយ ណេ ដា រូ សា ឡឹម | 1 | តួកគី | 1 |
| សហភាពអឺរ៉ុប | 1 | | |

Source: WIPO statistics database — January 2019

## 4.6. ការប៉ាន់ស្មានតម្លៃ និងការបង់កម្រៃ ការគណនាថ្លៃម៉ាឌ្រីដ មធ្យោបាយបង់ប្រាក់

ពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក ត្រូវតែភ្ជាប់ទៅជាមួយការបង់កម្រៃជាស្វីសហ្វ្រង់ (CHF) ទៅអង្គការ WIPO រួមមាន:

(១) កម្រៃមូលដ្ឋាន ៦៥ CHF ប្រសិនបើគំរូម៉ាកមិនមែនជាពណ៌ ឬ ៩0CHF ប្រសិនបើគំរូម៉ាកមានពណ៌។[2]

(២) កម្រៃតាមប្រទេសផ្ទាល់នីមួយៗ សម្រាប់ DCP នីមួយៗដែលបានកំណត់កម្រៃតាមប្រទេសផ្ទាល់ខ្លួន (សូមមើលតារាងខាងក្រោម) ។

(៣) កម្រៃបំពេញបន្ថែមចំនួន ១០០ CHF សម្រាប់ DCP នីមួយៗដែលមិនបានកំណត់កម្រៃតាមប្រទេសផ្ទាល់ខ្លួន និង

(៤) កម្រៃបន្ថែមបង្គ្រប់ចំនួន ១០០CHF សម្រាប់ទំនិញនិងសេវានីមួយៗលើសពីបីថ្នាក់ លើកលែងតែអ្នកជ្រើសរើសយកប្រទេសហត្ថលេខីដែលបានកំណត់កម្រៃតាមប្រទេសផ្ទាល់ខ្លួនប៉ុណ្ណោះ។

រហូតមកដល់ពេលនេះ ការិយាល័យម៉ាកចំនួន ៦០ នៃភាគីហត្ថលេខីនៃពិធីសារទីក្រុងម៉ាឌ្រីដបានគិតកម្រៃតាមប្រទេសផ្ទាល់ខ្លួន។ អ្នកអាចពិនិត្យមើលបញ្ជីការិយាល័យទាំងនេះ និងចំនួនដែលត្រូវទូទាត់នៅរាល់ប្រទេសនីមួយៗតាមរយៈអាសយដ្ឋាន http://www.wipo.int/madrid/en/fees/ind_taxes.html ។

ដើម្បីសម្រួលដល់ការគណនាកម្រៃដែលត្រូវបង់សម្រាប់ពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក អង្គការ WIPO ផ្តល់ជូននូវឧបករណ៍អនឡាញសម្រាប់អនុវត្តមួយ ដែលត្រូវបានគេស្គាល់ថាជា ឧបករណ៍គណនាកម្រៃ Fee Calculator ដែលអ្នកអាចប្រើបានតាមរយៈអាសយដ្ឋាន http://www.wipo.int/madrid/en /fees/calculator.jsp ។

*[2] ការបញ្ចុះកម្រៃគោលសម្រាប់ពាក្យស្នើសុំដែលដាក់ដោយអ្នកស្នើសុំពីប្រទេសដើមគឺជាប្រទេសអភិវឌ្ឍតិចតួច(LDC) យោងតាមបញ្ជីដែលបានបង្កើតឡើងដោយអង្គការសហប្រជាជាតិ។*

ទាក់ទងនឹងមធ្យោបាយទូទាត់អ្នកអាចបង់ថ្លៃសេវារបស់អ្នកទៅអង្គការ WIPO ដោយ(១)ការផ្ទេរប្រាក់តាមធនាគារ ឬ (២)គណនីចរន្តរបស់អង្គការ WIPO ។ សម្រាប់ព័ត៌មានលម្អិតសូមមើល http://www.wipo.int/about-wipo/en/finance / madrid.html ។

**គន្លឹះ**

*ពិនិត្យមើលជាមុនថាតើអ្នកនឹងត្រូវចំណាយប៉ុន្មានដោយប្រើប្រព័ន្ធគណនាតម្លៃតាមរយៈគេហទំព័រ http://www.wipo.int/madrid/en/fees/calculator.jsp.*

## 4.7. ការបញ្ជាក់ដោយ DIP និង ការដោះស្រាយភាពមិនប្រក្រតីដែលអាចកើតមាន

មុនពេលបញ្ជូនពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកទៅអង្គការ WIPO ហើយ DIP នឹងត្រួតពិនិត្យមើលថា: (១)អ្នកគឺជាបុគ្គលដូចគ្នាជាមួយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកកាន់កាប់ម៉ាកគោលនៅកម្ពុជា (២) ម៉ាកក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកដូចគ្នានឹងម៉ាកគោល និង (៣) ទំនិញ និងសេវានៅក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកមានគ្រប់ដូចម៉ាកគោល។ ប្រសិនបើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញ DIP នឹងបញ្ជាក់លើពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកហើយបញ្ជូនទៅ អង្គការ WIPO ដោយមានបញ្ជាក់អំពីកាលបរិច្ឆេទដែលពាក្យស្នើសុំអន្តរជាតិថាបានទទួលដោយ DIP ។

ប្រសិនបើអ្នកមានកំហុសក្នុងការធ្វើចាត់ចំណាត់ថ្នាក់ទំនិញ ឬសេវា ឬប្រសិនបើការបង្ហាញពីទំនិញ ឬសេវាណាមួយនៅក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក ត្រូវបានចាត់ទុកដោយអង្គការ WIPO ថាមិនច្បាស់លាស់ ភាសាមិនត្រឹមត្រូវ ឬ មិនអាចយល់បាន អង្គការ WIPO នឹងចេញសេចក្ដីជូនដំណឹងពីភាពមិនប្រក្រតី និងផ្ដល់ឲ្យ DIP រយៈពេលកំណត់ ៣ ខែដើម្បីធ្វើការកែតម្រូវតាមការចាំបាច់។

ក្នុងករណី មានកង្វះខាតមួយចំនួននៅក្នុងពាក្យស្នើសុំជាអន្តរជាតិរបស់អ្នក (ឧទាហរណ៍ អ្នកមិនបានបង្ហាញក្នុងការដាក់ពាក្យស្នើសុំរបស់អ្នកតាមរយៈ DIP ថាជាការិយាល័យដើម ឬពាក្យស្នើសុំរបស់អ្នកមិនត្រូវបានបង្ហាញក្នុងពាក្យស្នើសុំសំណុំបែបបទ MM២ ឬមិនត្រូវបានវាយបញ្ចូល ឬអត់បានចុះហត្ថលេខាដោយ DIP) អង្គការ WIPO នឹងចេញសេចក្ដីជូនដំណឹងពីភាពមិនប្រក្រតី និងផ្ដល់ឲ្យ DIP ក្នុងរយៈពេលបីខែដើម្បីដោះស្រាយបញ្ហាភាពមិនប្រក្រតីទាំងនោះ ហើយការខកខានឆ្លើយតបចំពោះពាក្យស្នើសុំជាអន្តរជាតិនោះនឹងត្រូវចាត់ទុកថាបោះបង់ចោលផងដែរ។

ដូចគ្នានេះដែរ ប្រសិនបើធាតុមួយ ឬច្រើនក្នុងពាក្យស្នើសុំជាអន្តរជាតិមិនមាន (ឈ្មោះ ឬ អាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំនៅ DIP កាលបរិច្ឆេទនិងលេខម៉ាកគោល គំរូម៉ាក បញ្ជីមុខទំនិញ និងសេវា ការបង្ហាញ DCPs ការបញ្ជាក់ភាពត្រឹមត្រូវរបស់ DIP) អង្គការ WIPO នឹងផ្ដល់ឱ្យ DIP រយៈពេលបីខែដើម្បីដោះស្រាយបញ្ហាមិនប្រក្រតីដូចជាការបរាជ័យដែលពាក្យស្នើសុំជាអន្តរជាតិនឹងត្រូវបានចាត់ទុកថាជាការបោះបង់ចោលផងដែរ។

ប្រសិនបើមានភាពមិនប្រក្រតីផ្សេងៗទៀត (ឧទាហរណ៍ អាសយដ្ឋានរបស់អ្នកមិនពេញលេញ គំរូម៉ាកមិនច្បាស់ មិនមានការបង់ប្រាក់ ឬចំនួនទឹកប្រាក់មិនគ្រប់គ្រាន់) ទាំងនេះនឹងត្រូវបានជូនដំណឹងដោយផ្ទាល់ដល់អ្នក និងគួរត្រូវបានដោះស្រាយដោយខ្លួនអ្នកផ្ទាល់ក្នុងរយៈពេលបីខែ ។ ការខកខានមិនបានធ្វើ ជាលទ្ធផលពាក្យស្នើសុំរបស់អ្នកត្រូវបានចាត់ទុកថាបោះបង់ចោល។

ជាចុងក្រោយ បើអ្នកបានជ្រើសរើសសហរដ្ឋអាមេរិក ហើយអ្នកមិនបានភ្ជាប់សំណុំបែបបទ MM១៨ ដែលមានប្រកាសពីគោលបំណងរបស់អ្នកដើម្បីប្រើប្រាស់ម៉ាកនៅសហរដ្ឋអាមេរិក អង្គការ WIPO នឹងបញ្ជាអ្នកតាមរយៈ DIP ដើម្បីភ្ជាប់បែបបទនោះក្នុងរយៈពេលពីរខែ ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំជាអន្តរជាតិដោយ DIP ។ ប្រសិនបើវាមិនត្រូវបានធ្វើនៅក្នុងអំឡុងពេលនោះទេ ការជ្រើសរើសយកសហរដ្ឋអាមេរិករបស់អ្នកនឹងត្រូវចាត់ទុកថាបានដកចេញ។

## 5. ការចុះបញ្ជីម៉ាកជាអន្តរជាតិ (IR)

ប្រសិនបើពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកអនុលោមតាមតម្រូវការ អង្គការ WIPO នឹងចុះបញ្ជីម៉ាករបស់អ្នកក្នុងបញ្ជីអន្តរជាតិ បោះផ្សាយការចុះបញ្ជីម៉ាកជាអន្តរជាតិ (IR) នៅលើព្រឹត្តិបត្រផ្លូវការម៉ាកជាអន្តរជាតិរបស់ អង្គការ WIPO និងជូនដំណឹងទៅការិយាល័យរបស់ប្រទេសហត្ថលេខីដែលបានជ្រើសរើស(DCPs)។ ការចុះបញ្ជីជាអន្តរជាតិក៏នឹងជូនដំណឹងដល់ DIP និងផ្ញើអ្នកនូវលិខិតបញ្ជាក់ការចុះបញ្ជីម៉ាកជាអន្តរជាតិផងដែរ។

### 5.1. កាលបរិច្ឆេទ និងប្រសិទ្ធភាព

#### 5.1.1. កាលបរិច្ឆេទនៃការចុះបញ្ជីជាអន្តរជាតិ

ជាវិធាន IR របស់អ្នកនឹងចុះកាលបរិច្ឆេទតាមពាក្យស្នើសុំជាអន្តរជាតិរបស់អ្នកដូចបានទទួលដោយ DIP លើកលែងតែពាក្យស្នើសុំរបស់អ្នកទៅដល់ អង្គការ WIPO លើសពីរខែបន្ទាប់ពីកាលបរិច្ឆេទនោះ (ករណីនោះ IR របស់អ្នកនឹងចុះកាលបរិច្ឆេទនៅពេលដែលបានទទួលយ៉ាងពិតប្រាកដដោយអង្គការ WIPO) ។

កាលបរិច្ឆេទ IR របស់អ្នកអាចត្រូវបានប៉ះពាល់ចាល ប្រសិនបើមានធាតុណាមួយដូចខាងក្រោមមិនត្រូវបានបំពេញ ឈ្មោះ និងអាសយដ្ឋានរបស់អ្នក ប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសដើម្បីការការពារ គំរូម៉ាក មុខទំនិញ ឬសេវាដែលត្រូវបានស្វែងរកការការពារម៉ាក ។ DIP នឹងត្រូវបានជូនដំណឹងអំពីភាពមិនប្រក្រតីបែបនេះ ដែលគួរតែត្រូវបានដោះស្រាយក្នុងរយៈពេលអតិបរមា ៣ ខែ។ កាលបរិច្ឆេទនៃ IR របស់អ្នកនឹងអាស្រ័យទៅលើកាលបរិច្ឆេទដែលធាតុបាត់ចុងក្រោយគេត្រូវបានទទួលដោយអង្គការ WIPO ។

#### 5.1.2. ប្រសិទ្ធភាពនៃការចុះបញ្ជីជាអន្តរជាតិ

ចាប់ពីថ្ងៃដែល IR របស់អ្នក ម៉ាករបស់អ្នកនឹងទទួលបានការការពារដូចគ្នានៅក្នុង DCP នីមួយៗ ដូចម៉ាករបស់អ្នកត្រូវបានដាក់ពាក្យសុំ ឬដាក់ពាក្យសុំដោយផ្ទាល់នៅក្នុង DCPនោះ ។

DCP អាចបដិសេធមិនការពារម៉ាករបស់អ្នកលើមូលដ្ឋានដូចគ្នាដែលអនុវត្តតាមច្បាប់ជាតិរបស់ខ្លួនទៅលើម៉ាកដាក់ផ្ទាល់ជាមួយការិយាល័យរបស់ DCP នោះ (ឧទាហរណ៍ ពីព្រោះម៉ាកនេះជាកម្មសិទ្ធិរបស់អ្នកផ្សេងទៀតនៅ DCP នោះ) ។ ការបដិសេធបែបនេះគឺជាប្រធានបទនឹងត្រូវពិនិត្យឡើងវិញ ឬបណ្តឹងជំទាស់ស្របតាមច្បាប់ និងការអនុវត្តរបស់ DCP ដែលពាក់ព័ន្ធ។ អ្នកអាចស្វែងរកព័ត៌មានអំពីការអនុវត្ត និងនីតិវិធីនៅក្នុងសមាជិកសហភាពម៉ាឌ្រីដ ដោយប្រព័ន្ធទិន្នន័យប្រវត្តិសមាជិករបស់អង្គការ WIPO នៅ http://www.wipo.int/madrid/memberprofiles/#/

ប៉ុន្តែផ្ទុយទៅវិញ DCP មួយមិនបដិសេធការការពារចំពោះម៉ាករបស់អ្នកក្នុងរយៈពេលកំណត់មួយ (១២ ខែ ឬ១៨ខែ ឬយូរជាង ១៨ខែក្នុងករណីមានការជំទាស់ពីភាគីទីបី) ឬប្រសិនបើការបដិសេធនេះត្រូវបានដកចេញនៅពេលបន្ទាប់ ការការពារម៉ាករបស់អ្នកនៅក្នុង DCP នឹងមានលក្ខណៈដូចគ្នា នឹងម៉ាកដែលដែលត្រូវបានចុះបញ្ជីដោយការិយាល័យ DCP ចាប់តាំងពីកាលបរិច្ឆេទ IR របស់អ្នក។

នៅក្នុងគ្រប់ DCP ទាំងអស់ដែលមិនបានបដិសេធការការពារម៉ាករបស់អ្នក នឹងមានសុពលភាពក្នុងរយៈពេល ១០ឆ្នាំគិតចាប់ពីកាលបរិច្ឆេទ IR មានលទ្ធភាពនៃការចុះបញ្ជីសាជាថ្មីឡើងវិញដោយមិនកំណត់សម្រាប់រយៈពេល១០ ឆ្នាំទៅមុខ។

**គន្លឹះ**

*ស្វែងយល់អំពីនីតិវិធី និងការអនុវត្តផ្សេងៗនៅក្នុងសមាជិកសហភាពម៉ាឌ្រីដតាមរយៈប្រព័ន្ធទិន្នន័យជីវប្រវត្តិសមាជិកម៉ាឌ្រីដតាមរយៈគេហទំព័រ http://www.wipo.int/madrid/memberprofiles/#/*

## 5.2. គ្រប់គ្រងការចុះបញ្ជីអន្តរជាតិរបស់អ្នក ការអនុវត្តល្អៗ

ខណៈពេលដែលប្រព័ន្ធម៉ាឌ្រីដផ្តល់ជូនអ្នកនូវគុណសម្បត្តិជាច្រើនដើម្បីទទួលបានការការពារម៉ាករបស់អ្នកនៅក្នុងទីផ្សារផ្សេងៗ វាផ្តល់ឱ្យអ្នកនូវគុណសម្បត្តិដ៏មានតម្លៃជាច្រើនទៀតទាក់ទងនឹងការគ្រប់គ្រងម៉ាករបស់អ្នកបន្ទាប់ពីការចុះបញ្ជី។ ការពង្រីកការការពារម៉ាករបស់អ្នកចំពោះដែនដីថ្មី ការចុះបញ្ជីសាជាថ្មីឡើងវិញ សម្រាប់រយៈពេល ១០ ឆ្នាំបន្ថែមទៀត ឬការផ្លាស់ប្តូរទិន្នន័យចុះបញ្ជីរបស់អ្នកដែលបានកត់ត្រានៅក្នុងបញ្ជីអន្តរជាតិដែលមានប្រសិទ្ធភាពដល់ការពង្រីកនូវសមាជិកសហភាពម៉ាឌ្រីដ ដែលអ្នកចាប់អារម្មណ៍ អាចធ្វើបានតាមរយៈ នីតិវិធីសាមញ្ញមួយ ងាយស្រួល និងការចំណាយដ៏ដោយសមស្រប។

### 5.2.1 ការពង្រីកការការពារនៅក្នុងដែនដីថ្មី (ការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម)

ប្រសិនបើអ្នកគឺជាម្ចាស់ IR ដែលមានបំណងចង់ពង្រីកការការពារដល់សមាជិកខ្លះនៃសហភាពម៉ាឌ្រីដ (ប្រទេសហត្ថលេខី) អ្នកអាចស្វែងរកការពង្រីកការការពារម៉ាករបស់អ្នកទៅតាមសមាជិកសហភាពម៉ាឌ្រីដផ្សេងទៀត នៅពេលណាក៏បាន ដែលមិនបានការជ្រើសរើសប្រទេសនោះពីមុន ក្នុងពាក្យស្នើសុំជាអន្តរជាតិដើមរបស់អ្នកទេ។ អ្នកគ្រាន់តែត្រូវបង្ហាញការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម ទៅអង្គការ WIPO តែប៉ុណ្ណោះ។

ការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែមត្រូវតែផ្ញើទៅ អង្គការ WIPO នៅក្នុងសំណុំបែបបទជាផ្លូវការ MM៤ (អាចទាញយកបានពីគេហទំព័រ http://www.wipo.int/madrid/en/forms/) ឬបញ្ជូនតាមអេឡិចត្រូនិកតាមរយៈ អង្គការ WIPO e-Subsequent ការសម្របសម្រួលការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែមអេឡិចត្រូនិក (https://www3.wipo.int/osd/)។ សម្រាប់ការសង្ស័យណាមួយអ្នកអាចទាក់ទងអង្គការ WIPO តាមអាសយដ្ឋាន https://www3.wipo.int/contact/en/madrid/

ក្នុងទំម្រង់បែបបទ MM៤ អ្នកត្រូវបញ្ជាក់ពីលេខដាក់ពាក្យចុះបញ្ជីអន្តរជាតិរបស់អ្នក ឈ្មោះ និងអាសយដ្ឋានរបស់អ្នក(ដូចបានកត់ត្រានៅក្នុងបញ្ជីអន្តរជាតិ) ភាគីចុះហត្ថលេខី ឬភាគីនានាដែលស្វែងរកបន្ថែមការការពារលើមុខទំនិញ និងសេវាដែលអ្នកបានជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម (ដែលអាចមានទាំងអស់ ឬក៏មានតែមួយគត់ដែលត្រូវតែមាននៅការចុះបញ្ជីម៉ាកជាអន្តរជាតិ)។ ទាក់ទងនឹងភាគីចុះហត្ថលេខីមួយចំនួន (សហភាពអឺរ៉ុប សហរដ្ឋអាមេរិក) អ្នកប្រហែលជាត្រូវបញ្ចូលព័ត៌មានបន្ថែមមួយចំនួន (ដូចមានបង្ហាញនៅក្នុងផ្នែក 4.5 ខាងលើ) ។

**ការជ្រើសរើសភាគីហត្ថលេខីបន្តបន្ទាប់បន្ថែម**



ARISE+
ASEAN Intellectual Property Rights

កម្រៃដែលត្រូវបង់សម្រាប់ការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម រួមមានកម្រៃមូលដ្ឋាន (៣០០ ស្វីសហ្វ្រង់), កម្រៃតាមប្រទេសផ្ទាល់នីមួយៗ សម្រាប់ DCP នីមួយៗដែលបានមានកំណត់កម្រៃ( http://www.wipo.int/madrid/en/fees/ind_taxes.html ) និងកម្រៃបំពេញបន្ថែម (១០០ ស្វីសហ្វ្រង់) សម្រាប់ DCP នីមួយៗ ដែលមិនមានកំណត់កម្រៃ។ ម៉ាស៊ីនគិតកម្រៃ ( http://www.wipo.int/madrid/en/fees/calculator.jsp )អាចត្រូវបានប្រើដើម្បីគណនាតម្លៃដែលត្រូវបង់ ។

ការជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែមនឹងចុះកាលបរិច្ឆេទនៅថ្ងៃដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកទទួលបាន ។

ប្រសិនបើ DCP មិនបដិសេធការការពារសម្រាប់ម៉ាករបស់អ្នកក្នុងរយៈពេលកំណត់ (១២ ខែ ១៨ ខែឬយូរជាង ១៨ ខែក្នុងករណីមានការជំទាស់ដោយភាគីទីបី) ឬប្រសិនបើការបដិសេធត្រូវបានដកចេញ ការការពារម៉ាករបស់អ្នកនៅនោះ DCP នឹងដកចេញដូចគ្នា ប្រសិនបើម៉ាករបស់អ្នកត្រូវបានចុះបញ្ជីដោយការិយាល័យ DCP នោះ ចាប់តាំងពីថ្ងៃដែលជ្រើសរើសប្រទេសបន្តបន្ទាប់បន្ថែម។

នៅគ្រប់ DCP ទាំងអស់ដែលមិនបដិសេធការការពារ ម៉ាករបស់អ្នកនឹងមានសុពលភាពសម្រាប់រយៈពេលដែលនៅសល់នៃ IR របស់អ្នក ហើយអាចចុះបញ្ជីសាជាថ្មីឡើងវិញដោយមិនកំណត់រយៈពេលសម្រាប់ ១០ ឆ្នាំបន្ថែមទៀត។

**គន្លឹះ**

*ដើម្បីពង្រីកការការពារដល់សមាជិកសហភាពម៉ាឌ្រីដថ្មី*
*សូមប្រើប្រព័ន្ធអេឡិចត្រូនិចជ្រើសរើសប្រទេសបន្ទាប់តាមរយៈគេហទំព័រ https://www3.wipo.int/osd/*

### 5.2.2 ការកត់ត្រាកណ្តាលលើការកែប្រែការចុះបញ្ជីជាអន្តរជាតរបស់អ្នក

នៅពេលណាមួយនាក្នុងអំឡុងពេលមានសុពលភាពនៃ IR របស់អ្នក អ្នកអាចស្នើសុំអង្គការ WIPO ដើម្បីកត់ត្រាក្នុងបញ្ជីអន្តរជាតិលើការផ្លាស់ប្តូរឈ្មោះ ឬអាសយដ្ឋាន ឬអ្នកតំណាង ការដាក់កំហិតដោយស្មគ្រចិត្ត ក្នុងកិច្ចការពារ IR (ការដាក់កម្រិត ការបោះបង់ ការលុបចេញ) ការប្តូរម្ចាស់កម្មសិទ្ធិនៃម៉ាក ឬអាជ្ញាប័ណ្ណ ដែលមានអានុភាពនៅក្នុង DCPs ទាំងអស់ ឬមួយចំនួន។ ដើម្បីស្នើសុំការកត់ត្រាលើការកែណាមួយប្រែបែបនេះ អ្នកត្រូវតែប្រើទម្រង់ផ្លូវការដែលមាននៅក្នុងគេហទំព័រ អង្គការ WIPO ( http://www.wipo.int/madrid/en/forms/ )។ ការកត់ត្រាកណ្តាលលើការកែប្រែទាំងនេះក្នុងបញ្ជីអន្តរជាតិ នឹងសម្រាលបន្ទុកអ្នកពីតម្រូវការចាំបាច់ឲ្យស្នើសុំចំណាត់ការបែបនេះពី DCP នីមួយៗ ដូច្នេះនឹងនាំមានការសន្សំសំចៃបានយ៉ាងច្រើន។

ដើម្បីស្នើសុំការកត់ត្រាលើការប្តូរឈ្មោះ ឬអាសយដ្ឋានរបស់អ្នកកាន់កាប់សិទ្ធិក្នុង IR (ដោយគ្មានការប្តូរម្ចាស់កម្មសិទ្ធិ) អ្នកត្រូវប្រើទម្រង់ MM៩។ សំណើរបស់អ្នកអាចយោងទៅលើ IR ជាច្រើន។ កម្រៃដែលអាចបង់ជូនអង្គការ WIPO នឹងមានចំនួន ១៥០ស្វីសហ្វ្រង់គត់។ ប្រសិនបើមានតែការប្តូរលើព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកដែលត្រូវកត់ត្រា (អាសយដ្ឋានសម្រាប់ការឆ្លើយឆ្លង អាសយដ្ឋានអ៊ីម៉ែល លេខទូរស័ព្ទ ឬលេខទូរសារ) គ្មានការបង់កម្រៃឡើយ។ ការប្តូរឈ្មោះ ឬអាសយដ្ឋានដែលបានកត់ត្រានៅក្នុងបញ្ជីអន្តរជាតិមានអានុភាពភ្លាមក្នុង DCPs ពាក់ព័ន្ធទាំងអស់ តាមរយៈ IR ដោយឥតគិតថ្លៃបន្ថែមឡើយ។

ប្រសិនបើអ្នកជាអ្នកកាន់កាប់សិទ្ធិនៃ IR ហើយមានបំណងផ្ទេរកម្មសិទ្ធិលើម៉ាករបស់អ្នកទៅម្ចាស់ថ្មីសម្រាប់ទំនិញនិងសេវាទាំងអស់ ឬមួយចំនួនដែលម៉ាកត្រូវបានការពារក្នុង DCPs ទាំងអស់ ឬមួយចំនួន អ្នកអាចស្នើសុំថាការប្តូរម្ចាស់កម្មសិទ្ធិត្រូវកត់ត្រានៅក្នុងបញ្ជីអន្តរជាតិ។ ការកត់ត្រាបែបនេះអាចកើតមានឡើង ប្រសិនបើម្ចាស់ថ្មីជាបុគ្គលមួយដែលមានសិទ្ធិប្រើប្រាស់ប្រព័ន្ធម៉ាឌ្រីដ (តាមរយៈសញ្ជាតិ ឬការបង្កើតអាជីវកម្ម ឬទីលំនៅក្នុងភាគីហត្ថលេខីមួយ)។ សំណើនេះអាចយោងទៅលើ IRs ជាច្រើនឲ្យតែការប្តូរម្ចាស់កម្មសិទ្ធិត្រូវអនុវត្តចំពោះ DCPs ទាំងអស់ ឬតែមួយ ហើយពាក់ព័ន្ធនឹងទំនិញនិងសេវាទាំងអស់ ឬដូចគ្នា។ ការស្នើសុំត្រូវដាក់ជូនអង្គការ WIPO ក្នុងទម្រង់ជាផ្លូវការ MM៥ ហើយត្រូវបង់កម្រៃ (១៧៧ស្វីស

**ការចុះបញ្ជីសាជាថ្មីឡើងវិញ /ការកែប្រែផ្សេងៗលើការចុះបញ្ជីជាអន្តរជាតិ**




ហ្វ្រង់)។ ការប្តូរម្ចាស់កម្មសិទ្ធិដែលត្រូវកត់ត្រានៅក្នុងបញ្ជីអន្តរជាតិនឹងមានអានុភាពភ្លាមក្នុង DCPs ពាក់ព័ន្ធទាំងអស់ដោយឥតគិតថ្លៃបន្ថែម។

ដើម្បីស្នើសុំការកត់ត្រាការប្តូរឈ្មោះ ឬអាសយដ្ឋានរបស់អ្នកតំណាង អ្នកត្រូវតែប្រើទម្រង់ MM១០។ ការកត់ត្រាការប្តូរបែបនេះមិនគិតថ្លៃឡើយ។

ដើម្បីស្នើសុំការដាក់កម្រិតបញ្ជីទំនិញនិងសេវាដែលអាចជះឥទ្ធិពលដល់ DCPs មួយចំនួន ឬទាំងអស់ អ្នកត្រូវតែប្រើទម្រង់ MM៦។ សំណើនេះត្រូវបង់កម្រៃ (១៧៧ស្វីសហ្វ្រង់) ជូនអង្គការ WIPO។ គ្មានកម្រៃបន្ថែមណាដែលត្រូវទាមទារដោយ DCPs ពាក់ព័ន្ធឡើយ។

ប្រសិនបើអ្នកមានបំណងកត់ត្រាការលះបង់នូវកិច្ចការពារសម្រាប់ទំនិញនិងសេវាទាំងអស់ក្នុង DCPs មួយចំនួន (មិនទាំងអស់ឡើយ) អ្នកត្រូវតែប្រើទម្រង់ MM៧។ ប្រសិនបើសំណើរបស់អ្នកពាក់ព័ន្ធនឹងការលុបចេញនូវ IR ចំពោះទំនិញនិងសេវាមួយចំនួន ឬទាំងអស់ ក្នុង DCPs ទាំងអស់ អ្នកត្រូវតែប្រើទម្រង់ MM៨។ សំណើទាំងនេះ (ការបោះបង់ និងការលុបចេញ) គឺមិនគិតកម្រៃឡើយ។

ប្រសិនបើអ្នកផ្តល់អាជ្ញាប័ណ្ណម៉ាករបស់អ្នក អ្នកអាចស្នើសុំការកត់ត្រាអាជ្ញាប័ណ្ណនៅក្នុងបញ្ជីអន្តរជាតិដោយបញ្ជាក់ឈ្មោះនិងអាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ។ DCPs ជាទីកន្លែងដែលអាជ្ញាប័ណ្ណត្រូវផ្តល់ ហើយទំនិញនិងសេវាសម្រាប់អាជ្ញាប័ណ្ណដែលត្រូវផ្តល់។ ការស្នើសុំត្រូវដាក់ជូនក្នុងទម្រង់ MM១៣ ហើយត្រូវបង់កម្រៃ ១៧៧ស្វីសហ្វ្រង់។ ការកត់ត្រាអាជ្ញាប័ណ្ណនៅក្នុងបញ្ជីអន្តរជាតិ នឹងមានអានុភាពតែនៅក្នុងប្រទេសដែលច្បាប់ក្នុងស្រុករបស់គេទាំងនោះផ្តល់ឲ្យមានការកត់ត្រាអាជ្ញាប័ណ្ណ ហើយមិនបានធ្វើការប្រកាសដែលបញ្ជាក់ថា ពួកគេមិនទទួលស្គាល់នូវអានុភាពនៃការកត់ត្រាអាជ្ញាប័ណ្ណនៅក្នុងបញ្ជីអន្តរជាតិឡើយ[3] ។

### 5.2.3 ការចុះបញ្ជីជាអន្តរជាតរបស់អ្នកសាឡើងវិញ

ដើម្បីធានាថាបន្ទាប់ពីរយៈពេល១០ឆ្នាំគិតចាប់ពីការចុះបញ្ជី ម៉ាករបស់អ្នកអាចបន្តកិច្ចការពារក្នុងរយៈពេល១០ឆ្នាំបន្ថែមទៀតនៅក្នុងដែនដីទាំងនោះដែលជាកន្លែងដែលអ្នកប្រាថ្នាចង់បានបែបនោះ ចាំបាច់អ្នកត្រូវបន្ត IR របស់អ្នកយ៉ាងសាមញ្ញ

*[3] សមាជិកសហភាពពិធីសារទីក្រុងម៉ាឌ្រីដចំនួន ១៨ បានប្រកាសថាពួកគេមិនទទួលស្គាល់អនុភាពនៃការកត់ត្រាអាជ្ញាប័ណ្ណនៅក្នុងបញ្ជីអន្តរជាតិឡើយ: OAPI កម្ពុជា ចិន កូឡុំប៊ី ហ្គាំប៊ី ហ្សកហ្ស៊ី ក្រិច ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន កៀហ្ស៊ីស៊ីស្ថាន ឡាវ ម៉ិកស៊ិកម៉ិកស៊ិក សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋម៉ូស្លីម សហព័ន្ធរុស្ស៊ី សិង្ហបុរីនិងថៃ។ នៅក្នុងភាគីទាំងនោះ អាជ្ញាប័ណ្ណទាំងអស់ត្រូវកត់ត្រាដោយផ្ទាល់ជាមួយការិយាល័យចុះបញ្ជីម៉ាករបស់ពួកគេដោយអនុលោមតាមច្បាប់ក្នុងស្រុក។*

ដោយបង់កម្រៃចាំបាច់ជូនអង្គការ WIPO។ កម្រៃកំណត់សម្រាប់ការបន្តរួមមានៈ កម្រៃគោល (៦៥៣ស្វីសហ្វ្រង់) កម្រៃដោយឡែកតាមប្រទេសសម្រាប់ DCP នីមួយៗដែលបានកំណត់កម្រៃមានក្នុងគេហទំព័រ (http://www.wipo.int/madrid/en/fees/ind_taxes.html) កម្រៃបំពេញគ្នាចំនួន (១០០ស្វីសហ្វ្រង់) សម្រាប់ DCP នីមួយៗដែលមិនបានបង្កើតប្រព័ន្ធកម្រៃដោយឡែកតាមប្រទេស និងកម្រៃបន្ថែម (១០០ស្វីសហ្វ្រង់) សម្រាប់ជំពូកនីមួយៗនៃទំនិញនិងសេវាដែលមានច្រើនជាងបីជំពូកឡើង។ លើកលែងតែអ្នកបន្តកិច្ចការពារនៅក្នុង DCPs ដែលបានកំណត់កម្រៃដោយឡែកតាមប្រទេស។

ប្រព័ន្ធសម្រាប់ការបន្ត IRs សាឡើងវិញតាមអេឡិចត្រូនិកមានក្នុងគេហទំព័ររបស់អង្គការ WIPO ហើយអាចប្រើប្រាស់ក្រោមសេវាតាមអេឡិចត្រូនិក (https://webaccess. wipo.int/trademarks_ren/?lang=EN)។ អ្នកអាចគណនាចំនួនទឹកប្រាក់ពិតប្រាកដដែលអ្នកត្រូវបង់សម្រាប់ការបន្ត IR របស់អ្នកដោយប្រើប្រាស់ Fee Calculator គណនាកម្រៃដែលមានក្នុងគេហទំព័រ (http://www.wipo.int/madrid/en/fees/calculator.jsp) របស់អង្គការ WIPO។ អ្នកអាចបង់កម្រៃបន្ត ការចុះបញ្ជីសាឡើងវិញរបស់អ្នកដោយប្រើប្រាស់ប័ណ្ណឥណទាន ឬគណនីចរន្តរបស់អង្គការ WIPO ប្រសិនបើអ្នកមាន។

កម្រៃបន្តការចុះបញ្ជីសាឡើងវិញគួរតែបង់ជូនអង្គការ WIPO យ៉ាងយឺតបំផុតនៅកាលបរិច្ឆេទផុតកំណត់នៃ IR។ ការទូទាត់នៅតែអាចធ្វើឡើងបានរហូតដល់ប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទនោះ (រយៈពេលអនុគ្រោះ) ឲ្យតែកម្រៃបន្ថែមត្រូវបង់នៅពេលជាមួយគ្នា។ អង្គការ WIPO កត់ត្រាការបន្តការចុះបញ្ជីសាឡើងវិញតាមកាលបរិច្ឆេទដែលការចុះបញ្ជីត្រូវបានកំណត់ទោះបីកម្រៃដែលតម្រូវ ត្រូវបានបង់នៅក្នុងកំឡុងពេលអនុគ្រោះនោះក៏ដោយ។

កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការបន្ត IR របស់អ្នកសាឡើងវិញ គឺមានដូចគ្នាចំពោះ DCPs ទាំងអស់។ នេះជាគុណសម្បត្តិច្បាស់លាស់ពីប្រព័ន្ធម៉ាឌ្រីដ បើប្រៀបធៀបទៅនឹងប្រព័ន្ធថ្នាក់ជាតិដែលជាកន្លែងដែលអ្នកមានម៉ាកផ្សេងៗគ្នា នៅតាមការិយាល័យចុះបញ្ជីម៉ាកដាច់ដោយឡែកពីគ្នាដែលត្រូវបន្តការចុះបញ្ជីសាឡើងវិញនៅកាលបរិច្ឆេទខុសៗគ្នា។

**គន្លឹះ**

*ដើម្បីចុះបញ្ជីសារឡើងវិញ IR របស់អ្នកសូមប្រើ the Madrid e-Renewal Service តាមរយៈគេហទំព័រ https://webaccess.wipo.int/trademarks_ren/?lang=EN*

## 5.3. ភាពមិនឯករាជ្យ និងការប្រែប្រួលក្នុងរយៈពេលប្រាំឆ្នាំ ភាពឯករាជ្យបន្ទាប់ពីរយៈពេលប្រាំឆ្នាំ

វាមានសារៈសំខាន់ណាស់ដែលអ្នកពិចារណាថា ក្នុងរយៈពេលប្រាំឆ្នាំ (រយៈពេលមានភាពមិនឯករាជ្យ) ជោគវាសនានៃ IR របស់អ្នក នឹងនៅតែពឹងផ្អែកទៅលើជោគវាសនានៃម៉ាកគោលរបស់អ្នក (ពាក្យសុំ ឬការចុះបញ្ជី) នៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើម៉ាកគោលនៅក្នុងប្រទេសកម្ពុជារបស់អ្នកឈប់មានអានុភាពទាំងស្រុង ឬមួយផ្នែក ដោយសារមូលហេតុណាមួយ (ការបដិសេធ ឬការដកពាក្យស្នើសុំចុះបញ្ជីគោលរបស់អ្នក ឬការលុបចេញ ការបោះបង់ ការដកហូតវិញ ការធ្វើមោឃភាព ឬការបញ្ចប់ផ្លូវច្បាប់នៃការចុះបញ្ជីគោលរបស់អ្នក) នៅក្នុងកំឡុងពេលនោះ (ប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃ IR របស់អ្នក)។ IR របស់អ្នកនឹងត្រូវលុបចេញទាំងស្រុង ឬមួយផ្នែក (សម្រាប់ទំនិញឬសេវាមួយចំនួនប៉ុណ្ណោះ) ទៅតាមនោះ។

ដើម្បីបន្ធូរពាល់ផលវិបាកពីទម្រង់នៃភាពមិនឯករាជ្យនេះ ពិធីសារទីក្រុងម៉ាឌ្រីដផ្តល់នូវលទ្ធភាពក្នុង ៉ការផ្លាស់ប្តូរ៉ នូវ IR របស់អ្នកទៅជាការដាក់ពាក្យស្នើសុំចុះបញ្ជីថ្នាក់ជាតិឬតំបន់នៅក្នុង DCPs នីមួយៗ។ ក្នុងរយៈពេល ៣ខែ គិតចាប់ពីការលុបចេញនូវ IR របស់អ្នក អ្នកអាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដូចគ្នានោះនៅក្នុង DCPs ទាំងនោះ ហើយពាក្យសុំចុះបញ្ជីទាំងនោះ (ដោយពឹងផ្អែកទៅលើ ៉ការផ្លាស់ប្តូរ៉ នូវ IR របស់អ្នក) នឹងត្រូវចាត់ទុកដូចពាក្យស្នើសុំចុះបញ្ជីទាំងនោះត្រូវបានដាក់នៅកាលបរិច្ឆេទនៃ IR ដើម (ដូច្នេះតម្កល់សិទ្ធិមានពីមុនដែលអ្នកទទួលបាន។

នៅចុងបញ្ចប់នៃរយៈពេលមានភាពមិនឯករាជ្យ ៥ឆ្នាំ IR របស់អ្នកក្លាយទៅជាមានភាពឯករាជ្យទាំងស្រុងពីម៉ាកគោលរបស់អ្នក ហើយមិនអាចត្រូវលុបចេញទៀតឡើយ ប្រសិនបើរឿងនេះកើតឡើងក្រោយ ដើម្បីបញ្ឈប់លែងឲ្យមានអានុភាពទៀត។

## 5.4. ឧបករណ៍អេឡិចត្រូនិកដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងការចុះបញ្ជីម៉ាកជាអន្តរជាតិ

បន្ថែមលើសេវាតាមអេឡិចត្រូនិកដែលបានបញ្ជាក់ខាងលើ ដែលជួយសម្រួលដល់ការរៀបចំបញ្ជីទំនិញនិងសេវា (MGS) ការដាក់ពាក្យស្នើសុំការជ្រើសរើសបន្ទាប់ ដោយប្រើប្រាស់ (e-Subsequent Designation) ការដាក់សំណើសុំបន្តការចុះបញ្ជីសាជាថ្មីឡើងវិញ (e-Renewal) និងការគណនាកម្រៃ (Fee Calculator) អង្គការ WIPO ផ្តល់សេវាតាមអេឡិចត្រូនិកចំនួនពីរផ្សេងទៀតដែលធ្វើឱ្យអ្នកងាយស្រួលជាង ដើម្បីត្រួតពិនិត្យ IR របស់អ្នក និង IR របស់គូប្រជែងរបស់អ្នក និងគ្រប់គ្រងថតផ្ទុកឯកសារ IR របស់អ្នក។ ខាងក្រោមនេះមានការពិពណ៌នាសង្ខេបអំពីសេវាទាំងពីរនេះ។

### 5.4.1. ឧបករណ៍ត្រួតពិនិត្យប្រព័ន្ធម៉ាឌ្រីដ

ម៉ាឌ្រីដម៉ូនីទ័រ (http://www.wipo.int/madrid/monitor/en/) គឺជាសេវាតាមអ៊ីឡិចត្រូនិករបស់អង្គការ WIPO ដែលផ្តល់ការចូលមើលព័ត៌មានអំពីម៉ាកដែលបានចុះបញ្ជីទាំងអស់ក្រោមប្រព័ន្ធម៉ាឌ្រីដ។ វាមានការប្រទាកគ្នាក្នុងស្រាវជ្រាវរកដែលមានលក្ខណៈពិសេសដោយផ្តល់នូវជម្រើសស្រាវជ្រាវរកជាច្រើន (ការស្រាវជ្រាវទូទៅ ការស្រាវជ្រាវកម្រិតខ្ពស់ ការស្រាវជ្រាវតាមការវិវត្តពេលវេលាជាក់ស្តែង ការស្រាវជ្រាវរូបភាព)។

ការប្រើប្រាស់មុខងារស្រាវជ្រាវតាមការវិវត្តពេលវេលាជាក់ស្តែងនៃម៉ាឌ្រីដម៉ូនីទ័រ អ្នកអាចតាមដានស្ថានភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីជាអន្តរជាតិរបស់អ្នក នៅពេលវាធ្វើចលនាឆ្លងកាត់ដំណើរការត្រួតពិនិត្យរបស់អង្គការ WIPO ហើយអ្នកអាចតាមដានភាពរីកចំរើននៃ IR របស់អ្នកនៅក្នុង DCP នីមួយៗ និងស្រាវជ្រាវថាតើកិច្ចការពារម៉ាករបស់អ្នកត្រូវបានផ្តល់ ឬបដិសេធនៅទីនោះ។

មុខងារស្រាវជ្រាវសទូទៅនិងស្រាវជ្រាវកម្រិតខ្ពស់ អនុញ្ញាតឱ្យអ្នកធ្វើការស្រាវជ្រាវរកនៅក្នុងទិន្នន័យក្នុងប្រព័ន្ធម៉ាឌ្រីដទាំងមូលតាមរយៈពាក្យ (ម៉ាក ទំនិញ ឬសេវា ឈ្មោះអ្នកកាន់កាប់សិទ្ធិ ឬតំណាង ការិយាល័យដើម DCP។ល។) លេខ (សម្រាប់ការចុះបញ្ជី ការស្នើសុំចុះបញ្ជីគោល, ចំណាត់ថ្នាក់ទីក្រុងនីស, ចំណាត់ថ្នាក់វីយែនណា។ល។) ឬការរួមបញ្ចូលគ្នា។ មុខងារស្រាវជ្រាវរករូបភាពអនុញ្ញាតឱ្យអ្នកធ្វើការស្រាវជ្រាវដោយជ្រើសរើសយករូបភាព ប្រភេទនៃរូបភាព ឬយុទ្ធសាស្ត្រស្រាវជ្រាវរករូបភាព។

ម៉ាឌ្រីដម៉ូនីទ័រក៏អនុញ្ញាតឱ្យអ្នកទាញយកព្រឹត្តិប័ត្ររបស់អង្គការ WIPO ស្តីពីម៉ាកជាអន្តរជាតិ (http://www.wipo.int/madrid/monitor/en/#gazettnd/) ការបោះពុម្ពផ្សាយប្រចាំសប្តាហ៍តាមប្រព័ន្ធម៉ាឌ្រីដដែលមានផ្ទុកទិន្នន័យថ្មីៗបំផុតទាក់ទងនឹង IRs ការបន្តការចុះបញ្ជីសាជាថ្មីឡើងវិញ ការជ្រើសរើសបន្ទាប់ និងការកែប្រែដែលជះឥទ្ធិពលដល់ការចុះបញ្ជីដែលមានស្រាប់។

ដើម្បីសម្របសម្រួលដល់ការត្រួតពិនិត្យម៉ាកផ្ទាល់ខ្លួនរបស់អ្នក និង/ឬ ម៉ាករបស់គូប្រជែងរបស់អ្នក ម៉ាឌ្រីដម៉ូនីទ័រផ្តល់ឱ្យអ្នកនូវលទ្ធភាពដើម្បីចុះឈ្មោះ ដើម្បីទទួលបាននូវការជូនដំណឹងតាមអ៊ីម៉ែលអំពីការផ្លាស់ប្តូរណាមួយដែលទាក់ទងទៅនឹងម៉ាករបស់អ្នក។ ដើម្បីទទួលសេវាជូនដំណឹងតាមអ៊ីម៉ែល អ្នកត្រូវមានគណនីប្រើប្រាស់ជាមួយអង្គការ WIPO ដែលអ្នកអាចបង្កើតបាននៅក្នុង https://www3.wipo.int/wipoaccounts/en/usercenter/public/register.jsf ។

### 5.4.2. ប្រព័ន្ធគ្រប់គ្រងប្រវត្តឯកសារម៉ាឌ្រីដ (MPM)

ការគ្រប់គ្រងថតផ្ទុកឯកសារម៉ាឌ្រីដ (MPM) គឺជាសេវាតាមអេឡិចត្រូនិករបស់អង្គការ WIPO ដែលនឹងអនុញ្ញាតឱ្យអ្នកគ្រប់គ្រងថតឯកសារចុះបញ្ជីម៉ាកជាអន្តរជាតិរបស់អ្នកដោយចូលទៅកាន់តាមរយៈគណនីមួយប្រកបសុវត្ថិភាព។ ដើម្បីប្រើប្រាស់ MPM អ្នកចាំបាច់ត្រូវមានគណនីអ្នកប្រើប្រាស់មួយនៅអង្គការ WIPO (https://www3.wipo.int/wipoaccounts/en/usercenter/public/register.jsf) ដោយភ្ជាប់ទៅនឹងអាសយដ្ឋានអ៊ីម៉ែលមួយ។ អ្នកអាចបង្កើតថតផ្ទុកឯកសារផ្ទាល់របស់អ្នក ដោយប្រមូល IRs ទាំងអស់ភ្ជាប់ទៅនឹងអាសយដ្ឋានអ៊ីម៉ែលតែមួយ។ ការប្រើប្រាស់ MPM អ្នកនឹងអាចដាក់សំណើសុំការផ្លាស់ប្តូរការបន្តការចុះបញ្ជីសាជាថ្មីឡើងវិញ និងការជ្រើសរើសបន្ទាប់ តាមដានស្ថានភាពនៃសំណើរបស់អ្នក បង់កម្រៃប្រតិភូកម្មភាពទទួលខុសក្នុងការគ្រប់គ្រងថតផ្ទុកឯកសារទាំងអស់ ឬមួយផ្នែករបស់អ្នក ពិនិត្យមើលនិងទាញយកឯកសារទំនាក់ទំនងពីការិយាល័យចុះបញ្ជីម៉ាកទាំងអស់ និងអង្គការ WIPO អំពីការចុះបញ្ជីដោយសុវត្ថិភាព និងស្នើសុំដកស្រង់ព័ត៌មានពីបញ្ជីអន្តរជាតិ។

# 6. ការការពារម៉ាករបស់អ្នកនៅក្នុងសហភាពអឺរ៉ុប

នៅក្នុងសហភាពអឺរ៉ុប (EU) មានប្រព័ន្ធបួនកំរិតជាន់សម្រាប់ចុះបញ្ជីម៉ាក។ អ្វីដែលអ្នកជ្រើសរើសអាស្រ័យលើភាពចាំបាច់នៃកិច្ចការជំនួញរបស់អ្នក។

ប្រសិនសិនបើអ្នកគ្រាន់តែមានបំណងទទួលបានកិច្ចការពារនៅក្នុងរដ្ឋជាសមាជិក EU ណាមួយ អ្នកអាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដោយផ្ទាល់នៅការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់ជាតិដែលពាក់ព័ន្ធ។ នេះជាច្រកថ្នាក់ជាតិ ដែលមានរដ្ឋជាសមាជិក EU ចំនួន ២៥ (ប្រទេសអូទ្រីស ប៊ុលហ្គារី ក្រូអាត ស៊ីព្រិក សាធារណរដ្ឋឆេក ដាណឺម៉ាក អេស្តូនី ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ក្រិច ហុងគ្រី អៀរឡង់ អ៊ីតា លីទ្បាតវី លីទុយអេន ម៉ាល់ត៍ ប៉ូឡូញ ព័រទុយហ្គាល់ រ៉ូម៉ានី ស្លូគី ស្លូវេនី អេស្ប៉ាញ ស៊ុយអែត និងចក្រភពអង់គ្លេស)។

ប្រសិនបើអ្នកមានបំណងទទួលបានកិច្ចការពារនៅក្នុងប្រទេស បែលហ្ស៊ិក លុចសំបួរ និងហូឡង់ អ្នកអាចដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅការិយាល័យកម្មសិទ្ធិបញ្ញា Benelux (BOIP) ដែលជាការិយាល័យកម្មសិទ្ធិបញ្ញាថ្នាក់តំបន់សម្រាប់កិច្ចការពារម៉ាកនៅរដ្ឋជាសមាជិកទាំងបីនោះ។ នេះជាច្រកថ្នាក់តំបន់ Benelux។

ប្រសិនបើអ្នកមានបំណងទទួលបានកិច្ចការពារនៅក្នុងរដ្ឋជាសមាជិក EU ជាច្រើន អ្នកអាចដាក់ពាក្យសុំចុះបញ្ជីម៉ាកក្រោមប្រព័ន្ធសហភាពអឺរ៉ុប (EUTM) ពីការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប (EUIPO) - នេះជាច្រកថ្នាក់តំបន់អឺរ៉ុប។ EUTM មានសុពលភាពនៅក្នុងទឹកដីនៃរដ្ឋជាសមាជិកសហភាព EU ទាំង២៨។

ច្រកទីបួនចំពោះកិច្ចការពារម៉ាកនៅក្នុង EU គឺច្រកថ្នាក់អន្តរជាតិ ឬច្រកប្រព័ន្ធម៉ាឌ្រីដដែលអាចរួមបញ្ចូលគ្នាជាមួយប្រព័ន្ធណាមួយក្នុងចំណោមប្រព័ន្ធទាំងបីខាងលើ។ បុគ្គលដែលដាក់ពាក្យសុំការចុះបញ្ជីជាអន្តរជាតិនៅក្រោមប្រព័ន្ធម៉ាឌ្រីដ អាចជ្រើសរើសសម្រាប់កិច្ចការពារក្នុងរដ្ឋជាសមាជិកសហភាពអឺរ៉ុបណាមួយ ដែលជាភាគីហត្ថលេខីនៃពិធីសារទីក្រុងម៉ាឌ្រីដដោយឡែកៗពីគ្នា ឬអាចជ្រើសរើសយក Benelux (សម្រាប់កិច្ចការពារនៅ បែលហ្ស៊ិក លុចសំបួរ និងហូឡង់) ឬអាចជ្រើសរើសយកសហភាពអឺរ៉ុប (សម្រាប់កិច្ចការពារនៅក្នុងរដ្ឋជាសមាជិក EU ទាំង ២៨ តាមរយៈការជ្រើសរើសរួមតែមួយ)។

ផ្នែកខាងក្រោមនេះដែលវិភាគអំពីអត្ថប្រយោជន៍ពីការទទួលសិទ្ធិលើម៉ាកដែលមានសុពលភាពក្នុងរដ្ឋជាសមាជិក EU ទាំង ២៨ ដោយអនុវត្តតាមទាំងច្រកថ្នាក់តំបន់ EU (ការដាក់ពាក្យដោយផ្ទាល់នៅ EUIPO) ឬទាំងច្រកថ្នាក់អន្តរជាតិ (ការដាក់ពាក្យតាមច្រក Madrid ដែលជ្រើសរើសយក EU) ។

## 6.1. ការដាក់ដោយផ្ទាល់ទៅកាន់ EUIPO (ច្រកថ្នាក់តំបន់អឺរ៉ុប)

ការដាក់ពាក្យស្នើសុំចុះបញ្ជី EUTM ដោយផ្ទាល់នៅ EUIPO ជំនួសឱ្យការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដាច់ដោយឡែកពីគ្នា ហើយការទទួលនូវសិទ្ធិដាច់ដោយឡែកពីគ្នាក្រោមប្រព័ន្ធនីមួយៗ នៃប្រព័ន្ធថ្នាក់ជាតិ និងប្រព័ន្ធ Benelux ដែលមានស្រាប់នៅក្នុង EU គឺជាច្រកដែលទាក់ទាញមួយ ប្រសិនបើមានបំណងទទួលបានសិទ្ធិរួមលើម៉ាកមួយដែលមានសុពលភាពនៅក្នុងរដ្ឋជាសមាជិក EU ទាំង២៨។

អ្នកអាចដាក់ពាក្យសុំចុះបញ្ជីតាមអេឡិចត្រូនិកនៅ EUIPO តាមរយៈគេហទំព័រ (https://euipo.europa.eu/ohimportal/en/apply-now)។ EUTM ផ្តល់ឱ្យអ្នកនូវសិទ្ធិផ្តាច់មុខដែលមានសុពលភាពនៅក្នុងរដ្ឋសមាជិក EU ទាំងអស់ (នាពេលបច្ចុប្បន្ន និងអនាគត) ក្នុងកម្រៃសមរម្យ (កម្រៃគោល ៨៥0EUR នៅឆ្នាំ ២០១៨ ចំពោះការដាក់ពាក្យតាមអេឡិចត្រូនិកនូវពាក្យស្នើសុំចុះបញ្ជី EUTM ដោយឡែកៗពីគ្នាក្នុងមួយជំពូក ចំពោះព័ត៌មានថ្មីៗស្តីពីកម្រៃដែលរួមបញ្ចូលជំពូកទំនិញ ឬសេវាបន្ថែម និងម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម EU សូមមើលគេហទំព័រ https://euipo.europa.eu/ohimportal/en/fees-payable-direct-to-euipo)។ EUTM មានសុពលភាពក្នុងរយៈពេល ១០ឆ្នាំ ហើយអាចបន្តការចុះបញ្ជីសាជាថ្មីឡើងវិញដោយឥតកំណត់រៀងរាល់១០ឆ្នាំម្តង។ អ្នកនឹងអាចអនុវត្តសិទ្ធិលើ EUTM របស់អ្នកនៅក្នុងទីផ្សារដែលមានអ្នកប្រើប្រាស់ជិត៥០០លាននាក់។

នៅក្នុងគេហទំព័ររបស់ EUIPO (https://euipo.europa.eu/ohimportal/en/trade-marks) អ្នកនឹងរកឃើញការពន្យល់លម្អិតស្តីពីធីរបៀបដាក់ពាក្យស្នើសុំចុះ EUTM របៀបអនុវត្តតាមនីតិវិធីចុះបញ្ជីម៉ាក និងរបៀបគ្រប់គ្រង EUTM នៅពេលបានចុះបញ្ជីរួច។

## 6.2. ការជ្រើសរើសយក EU តាមរយៈប្រព័ន្ធម៉ាឌ្រីដ (ច្រកថ្នាក់អន្តរជាតិ) និងការអនុវត្តល្អៗ

អត្ថប្រយោជន៍ស្រដៀងគ្នាទៅនឹងអត្ថប្រយោជន៍ដែលផ្តល់ដោយច្រកថ្នាក់តំបន់ EU ដោយរួមមានអត្ថប្រយោជន៍បន្ថែមដែលមានលក្ខណៈជាច់គេធៀបនឹងប្រព័ន្ធម៉ាឌ្រីដ ដែលអាចទទួលបានតាមរយៈការអនុវត្តច្រកថ្នាក់អន្តរជាតិ។ ចាប់តាំងពីឆ្នាំ ២០០៤ នៅពេលដែល EU បានក្លាយជាភាគីចុះហត្ថលេខីមួយនៃពិធីសារទីក្រុងម៉ាឌ្រីដ វាមានលទ្ធភាពទៀចសម្រាប់អ្នកប្រើប្រាស់ព័ន្ធម៉ាឌ្រីដ ដើម្បីទទួលបាននូវសិទ្ធិលើម៉ាកដែលមានអានុភាពដូចគ្នានឹង EUTM (មានសុពលភាពនៅក្នុងរដ្ឋជាសមាជិក EU ទាំងអស់) ដោយជ្រើសរើសយក EU ក្រោមនីតិវិធីអន្តរជាតិ (ទាំងក្នុងការស្នើសុំចុះបញ្ជីជាអន្តរជាតិ ទាំងការជ្រើសរើសយកបន្ទាប់)។

IR ដែលជ្រើសរើសយក EU ហើយត្រូវបានទទួលដោយ EUIPO ត្រូវមានអានុភាពដូចគ្នានឹង EUTM ដែលបានចុះបញ្ជីរួចដោយ EUIPO។ ផ្នែកនេះពិពណ៌នាពីការអនុវត្តល្អៗ ដែលត្រូវអនុវត្តតាមដើម្បីទទួលនិងគ្រប់គ្រង IR ដែលមានសុពលភាពនៅក្នុង EU។

### 6.2.1. ការជ្រើសរើសយកសហភាពអឺរ៉ុប និងលក្ខខណ្ឌតម្រូវជាក់លាក់

អ្នកអាចជ្រើសរើសសហភាពអឺរ៉ុបសម្រាប់កិច្ចការពារទាំង៖

i. នៅពេលដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីជាអន្តរជាតិនៅ DIP ដោយជ្រើសយកប្រអប់ (EM Code) របស់សហភាពអឺរ៉ុប នៅក្នុងទម្រង់ពាក្យស្នើសុំ (MM២) ឬ

ii. ពេលដែលអ្នកបានទទួល IR ដោយជ្រើសយកប្រអប់ (EM Code) របស់សហភាពអឺរ៉ុប នៅក្នុងទម្រង់ដែល ជ្រើសរើសយកបន្ទាប់ (MM៤) ដែលត្រូវបញ្ជូនទៅអង្គការ WIPO តាមប្រព័ន្ធអ៊ីឡិចត្រូនិក (https://www3.wipo.int/osd/) ឬតាមប៉ុស្តិ៍។

បន្ថែមលើលក្ខខណ្ឌតម្រូវជាទូទៅសម្រាប់ការស្នើសុំចុះបញ្ជីជាអន្តរជាតិ ឬការជ្រើសរើសយកបន្ទាប់នៅពេលដែលអ្នកជ្រើសរើសយក EU អ្នកគួរតែពិចារណាដូចខាងក្រោម៖

(ក) ភាសាក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខ EUIPO គឺជាភាសានៃការស្នើសុំចុះបញ្ជីជាអន្តរជាតិរបស់អ្នក (ភាសាអង់គ្លេស)។ ទោះបីយ៉ាងណាក៏ដោយ នៅពេលដែលជ្រើសរើសយក EU អ្នកត្រូវជ្រើសយកភាសាទី ២ មួយទៀតរបស់ EUIPO (ទាំងបារាំង អាល្លឺម៉ង់ អ៊ីតាលី ឬទាំងអេស្ប៉ាញ) ការប្រើប្រាស់ភាសាទី២ ដែលអ្នកទទួលយកជាភាសាដែលអាចប្រើប្រាស់ក្នុងកិច្ចដំណើរការនីតិវិធីប្តឹងជំទាស់ ដកយកវិញ ឬមោឃៈភាព។

(ខ) លើសពីនេះទៀត ប្រសិនបើអ្នកមានបំណងទាមទារសិទ្ធិអតីតភាព[4] លើម៉ាកដែលបានចុះបញ្ជីរួចមុនក្នុង ឬសម្រាប់រដ្ឋជាសមាជិក EU មួយ អ្នកអាចទាមទារសិទ្ធិនោះនៅពេលដែលដាក់ពាក្យស្នើសុំចុះបញ្ជីជាអន្តរជាតិ ឬការជ្រើសរើសយកបន្ទាប់ដោយភ្ជាប់ជាមួយទម្រង់ផ្លូវការ MM១៧ (អ្នកក៏អាចទាមទារសិទ្ធិអតីតភាពដោយផ្ទាល់នៅចំពោះមុខ EUIPO នៅកាលបរិច្ឆេទក្រោយ)។

កម្រៃគោលសម្រាប់ការជ្រើសរើសយក EU សម្រាប់មួយជំពូកទំនិញឬសេវា ត្រូវបានកំណត់ដោយ EUIPO ចំនួន៨៩៧ ស្វីសហ្វ្រង់ (នៅខែតុលា ២០១៨)។ សម្រាប់ព័ត៌មានថ្មីៗស្តីពីកម្រៃដោយឡែកតាមប្រទេសត្រូវកំណត់ដោយ EUIPO សម្រាប់ការជ្រើសរើស និងការបន្តការចុះបញ្ជីសាជាថ្មីឡើងវិញចំពោះម៉ាក និងម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ដោយឡែកៗក្រោមប្រព័ន្ធម៉ាឌ្រីដ សូមមើលគេហទំព័រ http://www.wipo.int/madrid/en/fees/ ind_taxes.html ។

*[4] ការទាមទារសិទ្ធិអតីតភាពជាប្រព័ន្ធមួយដែលតាមរយៈនោះម្ចាស់ពាក្យស្នើសុំចុះបញ្ជី/ការចុះបញ្ជី EUTM ឬការជ្រើសរើសយក EU នៅក្នុងការចុះបញ្ជីជាអន្តរជាតិ (IR) អាចទាមទារសិទ្ធិអតីតភាពពីការចុះបញ្ជីថ្នាក់ជាតិដែលមានស្រាប់ក្នុងសហភាពអឺរ៉ុប (ឬការជ្រើសរើសថ្នាក់ជាតិពីការចុះបញ្ជីជាអន្តរជាតិ) ទោះបីការចុះបញ្ជីថ្នាក់ជាតិត្រូវអនុញ្ញាតឲ្យបាត់សុពលភាពក៏ដោយ។*

### 6.2.2. ការតំណាងវិជ្ជាជីវៈនៅចំពោះមុខ EUIPO

ជាគោលការណ៍ អ្នកមិនចាំបាច់ចាត់តាំងអ្នកតំណាងនៅចំពោះមុខ EUIPO ឡើយ។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនបើនៅក្រៅតំបន់សេដ្ឋកិច្ច EU អ្នកចាំបាច់ត្រូវចាត់តាំងអ្នកតំណាងម្នាក់ (ក) ប្រសិនបើ EUIPO ចេញការបដិសេធបណ្តោះអាសន្នលើ IR របស់អ្នក (ខ) សម្រាប់ការដាក់ពាក្យស្នើសុំទាមទារសិទ្ធិអាតីតភាពដោយផ្ទាល់នៅចំពោះ EUIPO ឬ (គ) ឆ្លើយតបនឹងការជំទាស់ចុងក្រោយរបស់ EUIPO លើការទាមទារសិទ្ធិអាតីតភាព។ ក្នុងករណីបែបនេះ អ្នកតំណាងរបស់អ្នកគួរតែជាបុគ្គលដែលមានក្នុងទិន្នន័យអ្នកតំណាងដែលតម្កល់ដោយ EUIPO ក្នុងគេហទំព័របេ(https://euipo.europa.eu/eSearch/#advanced/representatives) ។

### 6.2.3. ការបោះពុម្ពឡើងវិញលើកដំបូង ការស្រាវជ្រាវ និងត្រួតពិនិត្យបែបបទ

នៅពេលទទួលបានសេចក្តីជូនដំណឹងរបស់អង្គការ WIPO ស្តីពី IR ដែលជ្រើសរើសយក EU EUIPO នឹងបោះពុម្ពផ្សាយសាឡើងវិញភ្លាមៗនូវ IR នៅក្នុងព្រឹត្តិបត្រ EUTM (ផ្នែកM.1) (https://euipo.europa.eu/eSearch/#advanced/bulletins)។ ការបោះពុម្ពផ្សាយត្រូវកំណត់ចំពោះទិន្នន័យប្រវត្តិរូប ដូចជា គំរូម៉ាក លេខជំពូកទំនិញឬសេវា ការ (មិនមែនបញ្ជីទំនិញនិងសេវាជាក់ស្តែងឡើយ)។ IR មានអានុភាពដូចគ្នា នៅពេលដែលពាក្យស្នើសុំចុះបញ្ជី EUTM ត្រូវបោះពុម្ពផ្សាយ ដោយគិតចាប់ពីថ្ងៃបោះពុម្ពផ្សាយសាឡើងវិញលើកដំបូង។

ប្រសិនបើ អ្នកមានបំណងបែបនោះ ក្នុងកំឡុងពេលមួយខែនៃការជូនដំណឹងរបស់អង្គការ WIPO អ្នកអាចស្នើសុំឲ្យ EUIPO រៀបចំរបាយការណ៍ស្រាវជ្រាវរបស់ EU ដែលដកស្រង់ EUTMs ដែលស្រដៀងគ្នា និង IRs IRs ដែលជ្រើសរើសយក EU។ អ្នកក៏អាចស្នើសុំ EUIPO ឲ្យបញ្ជូន IR ទៅកាន់ការិយាល័យថ្នាក់ជាតិនៃរដ្ឋជាសមាជិក EU ដើម្បីឲ្យមានការស្រាវជ្រាវថ្នាក់ជាតិជូនអ្នក (អ្នកនឹងត្រូវបង់កម្រៃឆ្លើយឆ្លង)។

ការត្រួតពិនិត្យបែបបទដែលអនុវត្តឡើងដោយ EUIPO អំពី IRs ត្រូវកំណត់ចំពោះ (ក) ថាតើភាសាទីពីរក្នុងកិច្ចដំណើរការនីតិវិធីត្រូវបានជ្រើសយកដែរឬទេ (ខ) ថាតើពាក្យស្នើសុំគឺសម្រាប់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម (គ) ថាតើមានការទាមទារសិទ្ធិអាតីតភាពឬទេ។ (ឃ) ថាតើបញ្ជីទំនិញនិង/ឬសេវាក្នុងការជ្រើសរើសយក EU ស្ថិតនៅក្នុងវិសាលភាពនៃបញ្ជីគោលរបស់ IR ឬទេ និង(ង) ថាតើការប្រើពាក្យពេចន៍ដើម្បីជ្រើសទំនិញ/សេវាទាំងនោះបំពេញតាមលក្ខខណ្ឌតម្រូវច្បាស់លាស់និងភាពជាក់លាក់ដូចបានរៀបរាប់នៅក្នុងផ្នែកខ ជំពូកទី៣ នៃសេចក្តីណែនាំលើម៉ាករបស់ EUIPO ឬទេ (https://euipo.europa.eu/ohimportal/en/trade -mark-guidelines) ។

ប្រសិនបើអ្នកខកខានមិនបានជ្រើសយកភាសាទីពីររបស់ EUIPO ជាភាសាដែលអាចប្រើប្រាស់បានសម្រាប់កិច្ចដំណើរការនីតិវិធីប្តឹងជំទាស់ ដកយកវិញ ឬមោឃៈភាពនៅចំពោះមុខ EUIPO EUIPO នឹងចេញការបដិសេធបណ្តោះអាសន្ន ហើយផ្តល់ឱ្យអ្នកនូវរយៈពេលពីរខែដើម្បីដោះស្រាយនូវភាពខ្វះចន្លោះនោះ។

ប្រសិនបើ IR របស់អ្នកដែលជ្រើសរើសយក EU គឺជាម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ដោយផ្អែកលើប្រភេទនៃម៉ាកបែបនេះនៅក្នុងប្រទេសកម្ពុជា IR នឹងត្រូវដោះស្រាយដូចគ្នានឹងម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្មរបស់ EU ដែលអាចអនុវត្តបានណាមួយ។ ក្នុងករណីបែបនេះ អ្នកចាំបាច់នឹងត្រូវដាក់បទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកជូន EUIPO ក្នុងរយៈពេលពីរខែ គិតចាប់ពីថ្ងៃដែលអង្គការ WIPO បានជូនដំណឹងទៅ EUIPO អំពីការជ្រើសរើសយកនោះ។

ប្រសិនបើ អ្នកបានទាមទារសិទ្ធិអាតីតភាពនៃម៉ាកដែលបានចុះបញ្ជីមុននៅក្នុងរដ្ឋជាសមាជិក EU ណាមួយ (ក្នុងទម្រង់ MM១៧) EUIPO នឹងពិនិត្យមើលថា អ្នកបានជ្រើសឈ្មោះរដ្ឋជាសមាជិក EU ដែលមានសិទ្ធិមុនដែលត្រូវចុះបញ្ជីជូន លេខចុះបញ្ជី និងកាលបរិច្ឆេទដាក់ពាក្យអំពីការចុះបញ្ជីដែលពាក់ព័ន្ធ។

ប្រសិនបើ អ្នកបានដាក់ឲ្យប្រើប្រាស់ពីការដាក់កម្រិតលើបញ្ជីទំនិញ និងសេវានៃ IR នៅក្នុងការជ្រើសយក EU EUIPO នឹងពិនិត្យមើលថា តើទំនិញនិងសេវានៅក្នុងបញ្ជីដែលដាក់កម្រិតរបស់អ្នកសម្រាប់ EU ត្រូវរួមបញ្ចូលក្នុងវិសាលភាពនៃបញ្ជីគោលនៃ IR ឬទេ។ ប្រសិនបើមិនដូច្នេះទេ EUIPO នឹងចេញការបដិសេធជាបណ្តោះអាសន្ន។

ប្រសិនបើ IR របស់អ្នកមានពាក្យពេចន៍សម្រាប់ទំនិញឬសេវាដែលខ្វះមានភាពច្បាស់លាស់ ឬភាពជាក់លាក់នោះ EUIPO នឹងចេញការបដិសេធជាបណ្តោះអាសន្ន ហើយផ្តល់ឱ្យអ្នកនូវរយៈពេលពីរខែ ដើម្បីដោះស្រាយនូវភាពខ្វះចន្លោះនោះ។

ដើម្បីជៀសវាងការរួមបញ្ចូលក្នុងបញ្ជីរបស់អ្នកនូវពាក្យជេចន៍ដែលនឹងមិនត្រូវទទួលយកដោយ EUIPO វាត្រូវណែនាំឲ្យអ្នកស្រាវជ្រាវរកមាតិកានៃ HDB ទិន្នន័យដែលបានធ្វើសុខដុមកម្មរបស់ EU មុនការដាក់ពាក្យ IR ដែលជ្រើសរើសយក EU។ ការស្រាវជ្រាវនេះអាចធ្វើឡើងតាមអេឡិចត្រូនិកដោយឥតគិតកម្រៃ តាមអាសយដ្ឋានគេហទំព័រដូចតទៅ: http://tmclass.tmdn.org/ec2/។ HDB មានពាក្យពេចន៍ដែលកំណត់ទំនិញនិងសេវាដែលត្រូវទទួលយកដោយការិយាល័យ TM ទាំងអស់ក្នុង EU។ រាល់ពាក្យពេចន៍ HDB នឹងត្រូវទទួលយកដោយ EUIPO ជាស្វ័យប្រវត្តិ។ នេះនឹងជួយធ្វើឱ្យដំណើរការចុះបញ្ជីរបស់អ្នកកាន់តែមានភាពរលូនជាង។

### 6.2.4. ការត្រួតពិនិត្យអំពីមូលដ្ឋានដាច់ខាតសម្រាប់ការបដិសេធ

IRs ដែលជ្រើសរើសយក EU ត្រូវអាស្រ័យលើការពិនិត្យអំពីមូលដ្ឋានដាច់ខាតសម្រាប់ការបដិសេធក្នុងមធ្យោបាយដូចគ្នានឹងការដាក់ពាក្យស្នើសុំចុះបញ្ជី EUTM ដោយផ្ទាល់។

ជាពិសេស ម៉ាករបស់អ្នកនឹងមិនមានភាពស្របច្បាប់ចំពោះកិច្ចការពារឡើយ ប្រសិនបើម៉ាកនោះមានសញ្ញាមួយដែល: (ក) មិនអនុលោមទៅតាមនិយមន័យ EUTM (អាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅនឹងទំនិញឬសេវារបស់សហគ្រាសមួយផ្សេងទៀត ហើយដែលត្រូវតំណាងក្នុងលក្ខណៈមួយដែលអាចជួយកំណត់កម្មវត្ថុឲ្យបានច្បាស់លាស់ និងជាក់លាក់ នៃកិច្ចការពារដែលត្រូវផ្ដល់ឲ្យ) (ខ) ខ្វះភាពញែកដាច់ (គ) មានលក្ខណៈពិពណ៌នា (ឃ) មានយ៉ាងផ្ដាច់មុខលើពាក្យ ឬការបង្ហាញដែលបានក្លាយទៅជាប្រពៃណី នៅក្នុងភាសាបច្ចុប្បន្ន ឬក្នុងភាពស្មោះត្រង់ និងបានបង្កើតការអនុវត្តក្នុងវិស័យពាណិជ្ជកម្មនៅតាមទីកន្លែងដែលពាក់ព័ន្ធឲ្យបានទាន់ពេលវេលា។ (ង) មានយ៉ាងផ្ដាច់មុខលើទម្រង់រូបរាងផលិតផល ឬចរិកលក្ខណៈផ្សេងៗទៀតដែលបានចេញមកពីទម្រង់ដើមនៃទំនិញ មានមុខងារបច្ចេកទេសសំខាន់ៗ ឬមានតម្លៃខ្ពស់។ (ច) គឺផ្ទុយនឹងគោលនយោបាយសាធារណៈ ឬគោលការណ៍សីលធម៌។ (ឆ) ជាទម្រង់បែបនោះទំនងជាបំភន្ត័សាធារណៈជនចំពោះទម្រង់ គុណភាព ឬប្រភពភូមិសាស្ត្រដើមនៃទំនិញ ឬសេវា។ (ជ) មានទំនាស់នឹងសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗរបស់រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលដែលបានការពារក្រោមមាត្រា៦ ស្ទួន ៣នៃអនុសញ្ញាប៉ារីស។ (ឈ) មានទំនាស់នឹងផ្លាកសញ្ញា និមិត្តសញ្ញា និងខែលនៃផលប្រយោជន៍សាធារណៈជាពិសេស (ញ) មានទំនាស់ជាមួយឈ្មោះប្រភពដើម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលត្រូវការពារក្រោមច្បាប់ជាតិ (រដ្ឋជាសមាជិក EU) ឬច្បាប់ជាតិអឺរ៉ុប ឬកិច្ចព្រមព្រៀងអន្តរជាតិដែល EU ឬរដ្ឋជាសមាជិកពាក់ពាន់ជាភាគី ។ (ដ)មានទំនាស់ជាមួយពាក្យប្រពៃណីសម្រាប់ស្រាដែលត្រូវការពារដោយច្បាប់របស់ EU ឬកិច្ចព្រមព្រៀងអន្តរជាតិដែល EU ជាសមាជិក។ (ឋ) មានទំនាស់ជាមួយនឹងផលិតផលប្រពៃណីពិសេសដែលត្រូវជានា (TSGs) ដែលត្រូវការពារដោយច្បាប់ EU ឬកិច្ចព្រមព្រៀងអន្តរជាតិដែល EU ជាសមាជិក។ (ឌ) មានទំនាស់ជាមួយឈ្មោះប្រភេទពូជរុក្ខជាតិផ្សេងៗដែលត្រូវការពារនៅក្នុង EU ចំពោះប្រភេទពូជរុក្ខជាតិផ្សេងៗនៃពន្ធុដូចគ្នា ឬដែលទាក់ទងជិតស្និទ្ធ។

ប្រសិនបើ EUIPO រកឃើញថា ម៉ាករបស់អ្នកមិនមានភាពស្របច្បាប់ចំពោះកិច្ចការពារ។ EUIPO នឹងបញ្ជូនការបដិសេធបណ្ដោះអាសន្ន និងផ្ដល់រយៈពេលពីរខែដើម្បីដាក់សេចក្ដីអង្កេត។ ការឆ្លើយតបរបស់អ្នកត្រូវបញ្ជូនដោយផ្ទាល់ទៅ EUIPO ដែលក្រោយពីធ្វើការពិនិត្យលើករណីនេះសាឡើងវិញ អាចសម្រេចដោយបញ្ជាក់ថានៅតែការបដិសេធ ឬលុបចេញការបដិសេធនោះ។

ប្រសិនបើ EUIPO រកឃើញថាម៉ាករបស់អ្នកមានមានភាពស្របច្បាប់ចំពោះកិច្ចការពារ ហើយឲ្យតែគ្មានការបដិសេធបណ្ដោះអាសន្នផ្សេងៗទៀតកំពុងរង់ចាំនោះទេ EUIPO នឹងបញ្ជូនជំហរបណ្ដោះអាសន្នទៅអង្គការ WIPO ដែលបញ្ជាក់ថាការត្រួតពិនិត្យដោយអំណាចនៃច្បាប់ត្រូវបានបញ្ចប់ ប៉ុន្តែ IR នៅតែបើកចំហរចំពោះការប្ដឹងជំទាស់ ឬការផ្ដល់សេចក្ដីអង្កេតរបស់ភាគីទីបី។

### 6.2.5. ការប្ដឹងជំទាស់

ការជំទាស់នឹងណាម្នាក់ដែលប្រើប្រាស់សិទ្ធិមានមុនដែលមានទំនាស់នឹងម៉ាករបស់អ្នក អាចដាក់ពាក្យប្ដឹងជំទាស់នឹង IR របស់អ្នក រវាងខែទីមួយ និងខែទីបួន បន្ទាប់ពីកាលបរិច្ឆេទបោះពុម្ពផ្សាយសាឡើងវិញលើកដំបូង។

ប្រសិនបើមានអ្នកណាម្នាក់ជំទាស់នឹង IR របស់អ្នកក្នុងអំឡុងពេលនោះ EUIPO នឹងបញ្ជូនសេចក្ដីជូនដំណឹងអំពីការបដិសេធបណ្ដោះអាសន្ន (ដោយផ្អែកលើមូលដ្ឋានដាច់ខាត) ទៅអង្គការ WIPO ហើយនឹងបញ្ជូនទៅអ្នកនូវច្បាប់ចំលងនៃ

សេចក្ដីជូនដំណឹងអំពីការជំទាស់នោះ។ EUIPO ក៏នឹងជូនដំណឹងដល់អ្នកអំពីពេលវេលាកំណត់សម្រាប់ការចាប់ផ្ដើមកិច្ចដំណើរការនីតិវិធី។ ក្នុងទំនាក់ទំនងទាំងអស់ជាមួយអង្គការ WIPO EUIPO នឹងប្រើភាសានៃ IR (ភាសាអង់គ្លេសនៅក្នុងករណីរបស់អ្នក)។ ចំនែក ក្នុងទំនាក់ទំនងទាំងអស់ដែលបានបញ្ជូនទៅអ្នកផ្ទាល់ EUIPO នឹងប្រើភាសានៃកិច្ចដំណើរការនីតិវិធីដែលត្រូវជ្រើសរើសដោយអ្នកប្ដឹងជំទាស់ (ដែលជាភាសាអង់គ្លេស ឬជាភាសាទីពីរដែលត្រូវជ្រើសរើសដោយអ្នកនៅពេលជ្រើសរើសយក EU) ។

ការបដិសេធបណ្ដោះអាសន្នអាចជាផ្នែកខ្លះ ឬទាំងអស់។ វានឹងកាន់កាប់សិទ្ធិមានមុនដែលត្រូវយកមកប្រើប្រាស់ បញ្ជីពាក់ព័ន្ធនឹងទំនិញនិងសេវាដែលការប្ដឹងជំទាស់ត្រូវពឹងផ្អែកទៅលើ ហើយក្នុងករណីដែលមានការបដិសេធផ្នែកខ្លះ បញ្ជីទំនិញនិងសេវាដែលការប្ដឹងជំទាស់ត្រូវសំដៅប្រឆាំងនឹង។ បញ្ជីទំនិញនិងសេវា នឹងប្រើភាសានៃកិច្ចដំណើរការនីតិវិធីប្ដឹងជំទាស់។

### 6.2.6. សេចក្ដីសម្រេចចុងក្រោយ

នៅពេលដែលនីតិវិធីទាំងអស់ត្រូវបានបញ្ចប់ហើយការសម្រេចទាំងអស់របស់ EUIPO បានបញ្ចប់ EUIPO ត្រូវបញ្ជូនការបដិសេធបណ្ដោះអាសន្នជូនអង្គការ WIPO ឬចេញសេចក្ដីថ្លែងការណ៍អំពីការផ្ដល់កិច្ចការពារជូនអង្គការ WIPO ដោយបញ្ជាក់អំពីទំនិញនិងសេវាដែលម៉ាករបស់អ្នកត្រូវទទួលយក។

### 6.2.7. ការបោះពុម្ពឡើងវិញជាលើកទី ២ និងការការពារនៅក្នុង EU

ប្រសិនបើ EUIPO សំរេចថា ម៉ាករបស់អ្នកត្រូវបានការពារ (យ៉ាងហោចណាស់ផ្នែកណាមួយ) ក្នុង EU EUIPO នឹងបោះពុម្ពផ្សាយ IR របស់អ្នកក្នុងរយៈពេលលើកទី ២ នៅក្នុងព្រឹត្តិបត្រ EUTM (រយៈពេលនេះមាននៅក្នុងផ្នែក M.៣)។ EUIPO នឹងមិនចេញវិញ្ញាបនប័ត្រចុះបញ្ជីណាមួយឡើយ។

ចាប់តាំងពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយសាឡើងវិញលើកទី ២ នេះ IR របស់អ្នកមានអានុភាពដូចគ្នានឹង EUTM ដែលត្រូវចុះបញ្ជីហើយអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នករំលោភបំពានណាមួយ។ កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយលើកទី ២ នេះក៏មានចំណុចចាប់ផ្ដើមសម្រាប់រយៈពេលប្រើប្រាស់ប្រាំឆ្នាំផងដែរ។ ប្រសិនបើម៉ាករបស់អ្នកមិនដាក់ឲ្យប្រើប្រាស់ដោយសុចរិតនៅក្នុង EU នៅក្នុងកំឡុងពេលនោះទេ អានុភាពនៃ IR របស់អ្នកនៅក្នុង EU អាចនឹងត្រូវបានប្រកាសថា មោឃៈ។

### 6.2.8. ការផ្លាស់ប្ដូរទៅជា EUTM

ប្រសិនបើ IR របស់អ្នកត្រូវបានលុបចេញទាំងស្រុង ឬមួយផ្នែកពីព្រោះម៉ាកគោលរបស់អ្នកនៅក្នុងប្រទេសកម្ពុជាបានឈប់មានអានុភាពក្នុងរយៈពេលនៃភាពមិនឯករាជ្យប្រាំឆ្នាំ ហើយការជ្រើសរើស EU របស់អ្នកនៅតែមានសុពលភាព អ្នកអាចដាក់ពាក្យស្នើសុំ EUTM ដោយផ្ទាល់នៅ EUIPO សម្រាប់ម៉ាកដូចគ្នា និងទំនិញ ឬសេវាដូចគ្នានឹងម៉ាកដែលបានលុបចេញ។ ដោយផ្អែកលើបទបញ្ញត្តិពិធីសារទីក្រុងម៉ាឌ្រីដ ស្ដីពី "ការផ្លាស់ប្ដូរ" ពាក្យសុំនេះនឹងត្រូវចាត់ទុកដោយ EUIPO ដូចពាក្យស្នើសុំចុះបញ្ជីត្រូវបានដាក់នៅកាលបរិច្ឆេទនៃការជ្រើសរើសយក EU ដើម ហើយនឹងទទួលបានសិទ្ធិអាទិភាពដូចគ្នា បើមាន។

ដើម្បីប្រើប្រាស់សិទ្ធិក្នុងការផ្លាស់ប្ដូរពាក្យស្នើសុំរបស់អ្នក គួរតែដាក់ក្នុងរយៈពេលបីខែចាប់ពីកាលបរិច្ឆេទដែល IR របស់អ្នកត្រូវបានលុបចេញទាំងស្រុងឬដោយផ្នែក ហើយទំនិញនិងសេវានៃពាក្យស្នើសុំចុះបញ្ជីដែលកើតឡើងក្រោយ គួរត្រូវដាក់បញ្ជីទំនិញនិងសេវានៃការជ្រើសរើយក EU។ នៅពេលដែលពាក្យសុំការផ្លាស់ប្ដូរ ដែលពាក់ព័ន្ធទៅនឹង IR ដែលជ្រើសរើយក EU ដែលត្រូវបានទទួលយក និងបានបោះពុម្ភផ្សាយរួចហើយ ដោយ EUIPO នោះ ដំណាក់ការត្រួតពិនិត្យនិងការប្ដឹងជំទាស់ត្រូវបានលុបចោល។ EUTM នឹងត្រូវបោះពុម្ភផ្សាយជាភាសា EU អស់ ហើយ វិញ្ញាបនប័ត្រចុះបញ្ជី EUTM នឹងត្រូវចេញជូន។

### 6.2.9. ការបម្លែង

ចំពោះហេតុផលណាមួយ ប្រសិនបើការជ្រើសរើសយក EU តាមប្រព័ន្ធម៉ាឌ្រីដរបស់អ្នក ត្រូវបានដកហូត បដិសេធ ឬឈប់មានអានុភាព អ្នកអាចស្នើសុំការបម្លែងការជ្រើសរើសយក EU នោះទៅជាពាក្យសុំចុះបញ្ជីថ្នាក់ជាតិ ដែលត្រូវដាក់ពាក្យផ្ទាល់ជាមួយការិយាល័យនៃរដ្ឋជាសមាជិក EU មួយ ឬច្រើន ឬការជ្រើសរើសយកបន្ទាប់នៃរដ្ឋជាសមាជិកទាំងនោះ នៅក្រោមប្រព័ន្ធម៉ាឌ្រីដ។ អានុភាពនៃការបម្លែងពាក្យសុំចុះបញ្ជីម៉ាកថ្នាក់ជាតិ ឬការជ្រើសរើសយកបន្ទាប់ ដែលចេញមកពីការបម្លែងត្រូវផ្តល់កាលបរិច្ឆេទដាក់ពាក្យដូចគ្នានឹងកការបរិច្ឆេទនៃការជ្រើសរើសយក EU ដែលបានកត់ត្រានៅក្នុងបញ្ជីអន្តរជាតិ (ហើយទទួលបានកាលបរិច្ឆេទអាទិភាព និង/ឬ អតីតភាពដូចគ្នាដែលទាមទារប្រសិនបើមាន)។ សម្រាប់ការជ្រើសរើសបន្ទាប់ដែលបានមកពីការបម្លែងត្រូវតែបញ្ជូនទៅអង្គការ WIPO តាមរយៈ EUIPO ក្នុងទម្រង់ផ្លូវការ (MM16) ក្នុង រយៈពេលបីខែ គិតចាប់ពីកាលបរិច្ឆេទដែលជ្រើសរើសយក EU ត្រូវបានបដិសេធ ឬដកហូតពាក្យ ឬឈប់មានអានុភាព។ សម្រាប់ព័ត៌មានលម្អិតស្តីពីការបម្លែង សូមមើលសេចក្តីណែនាំ EUIPO ផ្នែកផ្នែកE ចំនុចទី២ នៅក្នុងគេហទំព័រ https://euipo.europa.eu/ohimportal/en/trade-mark-guidelines ។

### 6.2.10. ការជំនួសនៅក្នុង EU

ប្រសិនបើម៉ាករបស់អ្នកបានចុះបញ្ជីនៅ EUIPO ជា EUTM រួចហើយ ហើយអ្នកជ្រើសរើសយក EU ក្រោមប្រព័ន្ធម៉ាឌ្រីដចំពោះម៉ាកដូចគ្នា អ្នកនឹងទទួលអត្ថប្រយោជន៍ពីពិធីសារម៉ាឌ្រីដពីការជំនួស (សិទ្ធិលើ IR របស់អ្នកនៅក្នុង EU នឹងត្រូវបានចាត់ទុកថា ចាប់ផ្តើមពីកាលបរិច្ឆេទនៃការចុះបញ្ជី EUTM មុន)។ ការជំនួសធ្វើឡើងដោយស្វ័យប្រវត្តិដោយមិនចាំបាច់ត្រូវស្នើសុំកត់ត្រាណាមួយឡើយ។ ទោះបីយ៉ាងណាក៏ដោយ អ្នកអាចស្នើសុំ EUIPO ឱ្យកត់សម្គាល់អំពីការជំនួសនៅក្នុងបញ្ជីរបស់ខ្លួន។ បន្ទាប់ពីការជំនួសត្រូវបានធ្វើឡើង EUTM ត្រូវតែម្កល់ជាធម្មតានៅក្នុងការចុះបញ្ជីរបស់ខ្លួន រហូតដល់អ្នកបន្តការចុះបញ្ជីសាជាថ្មីឡើងវិញ។ ប្រសិនបើអ្នកបន្តការចុះបញ្ជី EUTM សាឡើងវិញនេះ វានឹងមានសិទ្ធិរួមគ្នា រវាង EUTM "ដែលត្រូវជំនួស" និង IR ដែលបានជ្រើសរើសយក EU ។

## 7. សេចក្តីសន្និដ្ឋាន

ពិធីសារទីក្រុងម៉ាឌ្រីដផ្តល់ឱ្យអ្នកនូវច្រកដែលទាក់ទាញដើម្បីការពារម៉ាកយីហោរបស់អ្នក នៅក្នុងប្រទេសរហូតដល់ទៅ ១១៧ នៅជុំវិញពិភពលោក ដោយផ្តល់នូវថ្លៃសមរម្យ និងនីតិវិធីងាយស្រួលប្រើប្រាស់ដើម្បីទទួលនិងគ្រប់គ្រងសិទ្ធិលើម៉ាករបស់អ្នកនៅបរទេស។ ជាជនជាតិកម្ពុជា ឬបុគ្គលណាម្នាក់ដែលទីលំនៅស្របច្បាប់ ឬមានសហគ្រាសនៅក្នុងប្រទេសកម្ពុជា អ្នកមានសិទ្ធិប្រើប្រាស់សន្ធិសញ្ញានេះដែលប្រទេសកម្ពុជាបានចូលរួមក្នុងឆ្នាំ ២០១៥។ សព្វថ្ងៃនេះ ការប្រើប្រាស់ពិធីសារទីក្រុងម៉ាឌ្រីដគឺជាផ្នែកដ៏សំខាន់មួយនៃយុទ្ធសាស្ត្រកសាងម៉ាកយីហោប្រកបដោយជោគជ័យ។ ពិធីសារនេះផ្តល់ជូនអ្នកនូវវត្តមានម៉ាកយីហោឲ្យបានមុនគេនៅកម្រិតសកល ហើយជួយអ្នកឲ្យទទួលបានកិត្តិនាមជាអន្តរជាតិយ៉ាងឆាប់រហ័ស និងបង្កើតតម្លៃសុច្ឆន្ទៈសម្រាប់ម៉ាករបស់អ្នកនៅបរទេស។ ពិធីសារនេះជានាកិច្ចការពារផ្នែកច្បាប់លើម៉ាកយីហោរបស់អ្នកប្រឆាំងនឹងអ្នកប្រកួតប្រជែងក្នុងទីផ្សារនាំចេញ បង្កើនឱកាសផ្តល់ហ្វ្រែនឆាយ បើកទូលាយលទ្ធភាពដល់ភាពជាដៃគូ និងជួយសម្រួលដល់ការធ្វើសមាហរណកម្មដល់ចង្វាក់ផ្គត់ផ្គង់ជាសកល។ ជាទូទៅពិធីសារទីក្រុងម៉ាឌ្រីដផ្តល់នូវការគាំទ្រដ៏មានប្រសិទ្ធភាពបំផុតចំពោះយុទ្ធសាស្ត្រកាសាងម៉ាកយីហោ និងភាពជោគជ័យក្នុងអាជីវកម្មរបស់អ្នក។

## សមាជិកសហភាពពិធីសារទីក្រុងម៉ាឌ្រីដ

សមាជិកចំនួន ១០២ (រួមទាំងសហភាពអឺរ៉ុប និងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក)
គ្របដណ្តប់ប្រទេសចំនួន ១១៨ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨



អាហ្វហ្គានីស្ថាន អង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក (OAPI)[5] អាល់បានី អាល់ហ្សេរី អង់ទីហ្គា និងបាប៊ីដ អាមេនី អូស្ត្រាលី អូទ្រីស អាហ្សែ បែប៊ិង់បារ៉ែន បេឡារុស្ស ប៊ែលហ្ស៊ិក ប៊ូតង់ បូស្នៀ និងហឺហ្ស៊េហ្គោវីណា បុិតស្វាណា ប្រ៊ុយណេដារូសាឡឹម ប៊ុលហ្គារី កម្ពុជា ចិន កូឡុំប៊ី ក្រូអាត គុយបា ស៊ីប សាធារណរដ្ឋឆែក សាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ ដាណឺម៉ាក អេហ្ស៊ីព អេស្តូនី អេស្វាទីនី សហភាពអឺរ៉ុបហ្វាំងឡង់ បារាំង ហ្គាំប៊ី ហ្សកហ្ស៊ី អាឡឺម៉ង់ ហ្គាណា ក្រិក ហុងគ្រី អ៊ីស្លង់ ឥណ្ឌា ឥណ្ឌូនេស៊ី អ៊ីរ៉ង់ អ៊ីតាលីអ៊ីតាលី ជប៉ុន កាហ្សាក់ស្ថាន កេនយ៉ា កៀហ្ស៊ីស៊ីស្ថាន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ លីត្វានីអូតួ លីបេរីយ៉ា លីតចិនស្ទីន លីទុយអានី លុចសំបួ ម៉ាដាហ្គាស្ការ ម៉ាឡាវី មិុកស៊ិក ម៉ូណាកូ ម៉ុងហ្គោលី ម៉ុងតេក្រូ ម៉ារ៉ុក ម៉ូហ្សំប៊ិក ណាមីប៊ី ហូឡង់ នូវែលសេឡង់ ន័រវេ អូម៉ាន ហ្វីលីពីន ប៉ូឡូញ ព័រទុយហ្គាល់ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋម៉ុលដាវី រ៉ូម៉ានី សហព័ន្ធរុស្ស៊ី រ្វ៉ាន់ដា សានម៉ារីណូ សៅតូម៉េនិងព្រីនខិស ស៊ីប៊ី សៀរ៉ាឡេអូន សាំងហ្គាពួរ ស្លូវ៉ាគី ស្លូវេនី អេស្ប៉ាញ ស៊ូដង់ ស៊ុយអែត ស្វីស សាធារណរដ្ឋអារ៉ាប់ ស៊ីរីតាជីគីស្ថាន ថៃ អតីតសាធារណរដ្ឋយូហ្គោស្លាវីម៉ាសេឌូនី ទុយនីស៊ី ទួរគីតួកម៉េនីស្ថាន អ៊ុយក្រែន ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក អ៊ូសបេគីស្ថាន វៀតណាម ហ្សំបៀ ហ្ស៊ីមបាវ៉េ (102)

*[5] ការជ្រើសរើសយក OAPI នៃពិធីសារទីក្រុងម៉ាឌ្រីដ ដែលគ្រប់ដណ្តប់រដ្ឋជាសមាជិករបស់ខ្លួនរួមមាន: បេនីន ប៊្រុគីណាហ្វាសូ កាមេរូន សាធារណរដ្ឋអាហ្វ្រិកកណ្តាល ឆាដ កូម័រដូ កុនដូ អេក្វាទ័រហ្គីណេ ហ្គាបុង ហ្គីណេប៊ីសៅ ហ្គីណេម៉ាលី ម៉ូរីតានី,នីហ្សេរីយ៉ា សេណេហ្គាល់ តូហ្គោ (១៧)។*

*[6] ការស្នើសុំតាមម៉ាឌ្រីដជ្រើសរើសយកសហភាពអឺរ៉ុបគ្របដណ្តប់គ្រប់រដ្ឋជាសមាជិករបស់ខ្លួនរួមមាន: អូទ្រីស បែលហ្ស៊ិក ប៊ុលហ្គារី ក្រូអាត ស៊ីប សាធារណរដ្ឋឆែក ដាណឺម៉ាក អេស្តូនី ហ្វាំងឡង់បារាំង អាល្លឺម៉ង់ ក្រិច ហុងគ្រី អៀឡង់ អ៊ីតាលី ឡាតវី លីទុយអានី លុចសំបួ ម៉ាល់តា ហូឡង់ ប៉ូឡូញ ព័រទុយហ្គាល់ រូម៉ានី ស្លូវ៉ាគី ស្លូវេនី អេស្ប៉ាញ ស៊ុយអែត ចក្រភពអង់គ្លេស (២៨)*

## អក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **BOIP** | ការិយាល័យកម្មសិទ្ធិបញ្ញា Benelux |
| **CHF** | ស្វីសហ្វ្រង់ |
| **DCP** | ភាគីហត្ថលេខីដែលត្រូវជ្រើសរើស |
| **DIP** | នាយកដ្ឋានកម្មសិទ្ធិបញ្ញានៅក្នុងក្រសួងពាណិជ្ជកម្មនៃប្រទេសកម្ពុជា |
| **EM** | កូដមានពីរអក្សរដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណសហគមន៍អឺរ៉ុបនៅក្នុងសំណុំបែបបទពិធីសារម៉ាឌ្រីដ |
| **EU** | សហភាពអឺរ៉ុប |
| **EUIPO** | ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប |
| **EUTM** | ម៉ាកសហភាពអឺរ៉ុប |
| **IA** | ពាក្យស្នើសុំចុះបញ្ជីជាអន្តរជាតិ |
| **IR** | ការចុះបញ្ជីជាអន្តរជាតិ |
| **MGS** | ការគ្រប់គ្រងជំពូកទំនិញនិងសេវារបស់ម៉ាឌ្រីដ |
| **OAPI** | អង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក |
| **WIPO** | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |

## សទ្ទានុក្រម

| | |
|---|---|
| **ម៉ាកគោល** | ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬការចុះបញ្ជីនៅក្នុងសមាជិកមួយរបស់សហភាពម៉ាឌ្រីដ ដែលជាមូលដ្ឋានសម្រាប់ការដាក់ពាក្យចុះបញ្ជីម៉ាកជាអន្តរជាតិ |
| **ភាគីហត្ថលេខី** | រដ្ឋនិងអង្គការអន្តររដ្ឋាភិបាលដែលជាភាគីនៃពិធីសារទីក្រុងម៉ាឌ្រីដ |
| **ការស្នើសុំចុះបញ្ជីជាអន្តរជាតិ** | ការស្នើសុំចុះបញ្ជីម៉ាកក្រោមនីតិវិធីពិធីសារទីក្រុងម៉ាឌ្រីដ |
| **ការចុះបញ្ជីម៉ាកជាអន្តរជាតិ** | ការចុះបញ្ជីម៉ាកជាអន្តរជាតិក្រោមនីតិវិធីពិធីសារម៉ាឌ្រីដ |
| **សហភាពម៉ាឌ្រីដ** | សហភាពរដ្ឋ និងអង្គការអន្តររដ្ឋាភិបាលដែលជាភាគីនៃពិធីសារទីក្រុងម៉ាឌ្រីដ |
| **ពិធីសារទីក្រុងម៉ាឌ្រីដ** | ពិធីសារឆ្នាំ១៩៨៩ ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ ស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ |
| **ប្រព័ន្ធម៉ាឌ្រីដ** | ប្រព័ន្ធម៉ាឌ្រីដសម្រាប់ការចុះបញ្ជីម៉ាកជាអន្តរជាតិដែលគ្រប់គ្រងដោយពិធីសារទីក្រងម៉ាឌ្រីដ និងគ្រប់គ្រងដោយអង្គការ WIPO |
| **សមាជិកសហភាពម៉ាឌ្រីដ** | ភាគីហត្ថលេខីនៃពិធីសារទីក្រុងម៉ាឌ្រីដ |
| **ចំណាត់ថ្នាក់ទីក្រុងនីស** | ចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាសម្រាប់គោលបំណងនៃការចុះម៉ាកដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងនីស ឆ្នាំ ១៩៥៧ បានធ្វើវិសោធនកម្មនៅឆ្នាំ១៩៧៩ |
| **ការជ្រើសរើសយកបន្ទាប់** | សំណើសុំពង្រីកកិច្ចការពារនៃការចុះបញ្ជីអន្តរជាតិនៅភាគីហត្ថលេខីបន្ថែមមួយ ឬច្រើន។ |

## ឧបករណ៍អនឡាញ និងសេវាផ្សេងៗដែលអាចរកបានដោយសេរី សម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធម៉ាឌ្រីដ

**ASEAN TMclass** – http://www.asean-tmclass.org/ec2/
ឧបករណ៍តាមអេលិចត្រូនិកដែលសម្រួលការកំណត់អត្តសញ្ញាណនិងការចាត់ថ្នាក់ទំនិញនិងសេវាសម្រាប់ការចុះបញ្ជីម៉ាក នៅក្នុងការិយាល័យកម្មសិទ្ធិបញ្ញាអាស៊ានទាំងអស់។

**ASEAN TMview** – http://www.asean-tmview.org/tmview/welcome
វេទិកាពត៌មានដែលអាចស្រាវជ្រាវរកបាននៅក្នុងទិន្នន័យម៉ាកនៃការិយាល័យកម្មសិទ្ធិបញ្ញាអាស៊ានទាំងប្រាំបួន។

**E-Subsequent Designation** – https://www3.wipo.int/osd/
ប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការដាក់ពាក្យជ្រើសរើសយកបន្ទាប់ក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

**EUIPO Representatives Database** – https://euipo.europa.eu/eSearch/#advanced/representatives
ទិន្នន័យអំពីអ្នកតំណាងដែលបានតម្កល់ដោយការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប

**EUIPO Trade Mark Guidelines** – https://euipo.europa.eu/ohimportal/en/trade-mark-guidelines
គោលការណ៍ណែនាំអំពីការអនុវត្តរបស់ EUIPO ដែលទាក់ទងនឹងនីតិវិធី EUTM

**EUIPO Trade Mark website** – https://euipo.europa.eu/ohimportal/en/trade-marks
គេហទំព័រអំពីម៉ាករបស់ការិយាល័យកម្មសិទ្ធិបញ្ញាសហភាពអឺរ៉ុប

**EUTM Bulletin** – https://euipo.europa.eu/eSearch/#advanced/bulletins
ការបោះពុម្ពផ្សាយជាផ្លូវការរបស់ EUIPO ដែលមានទិន្នន័យថ្មីៗទាក់ទងនឹងការចុះបញ្ជី EUTM

**EUTM Fees** – https://euipo.europa.eu/ohimportal/en/fees-payable-direct-to-euipo
កម្រៃដែលអាចបង់សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជី EUTM និងនីតិវិធីទាក់ទងនឹង EUTM ផ្សេងទៀត

**EUTM online filing** – https://euipo.europa.eu/ohimportal/en/apply-now
ប្រព័ន្ធអេឡិកត្រូនិកសម្រាប់ការដាក់ពាក្យ EUTM តាមអេឡិចត្រូនិកនៅក្នុងគេហទំព័ររបស់ EUIPO

**Fee Calculator** – http://www.wipo.int/madrid/en/fees/calculator.jsp
ឧបករណ៍តាមអេឡិចត្រូនិកដែលគ្រប់គ្រងដោយអង្គការ WIPO ដែលសម្រួលការគណនាកម្រៃដែលត្រូវបង់សម្រាប់ការស្នើ ស្នើសុំចុះបញ្ជីជាអន្តរជាតិ ការជ្រើសរើសយកបន្ទាប់ និងការបន្តការចុះបញ្ជីសាឡើងវិញក្រោមប្រព័ន្ធម៉ាឌ្រីដ។

**Global Brand Database** – http://www.wipo.int/branddb/en/index.jsp
ច្រកអេឡិកត្រូនិករបស់ WIPO ដែលមានកំណត់ត្រាជាង ៣៦លាន មកពីការប្រមូល (ម៉ាក ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ និមិត្តសញ្ញារដ្ឋ។ល។)

**Madrid E-Renewal** – https://webaccess.wipo.int/trademarks_ren/?lang=EN
មធ្យោបាយអេឡិចត្រូនិកដើម្បីស្នើសុំការបន្តការចុះបញ្ជីជាអន្តរជាតិសាឡើងវិញក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

**Madrid Forms** – http://www.wipo.int/madrid/en/forms/
អាសយដ្ឋានគេហទំព័ររបស់អង្គការ WIPO ដែលអាចទាញយកសំណុំបែបបទម៉ាឌ្រីដ

**Madrid Goods and Services Manager (MGS)** – https://webaccess.wipo.int/mgs/
ឧបករណ៍អេឡិចត្រូនិកគ្រប់គ្រងដោយអង្គការ WIPO ដែលជួយចងក្រងបញ្ជីទំនិញនិងសេវាដែលត្រូវបញ្ជូននៅពេលដាក់ពាក្យសុំចុះបញ្ជីជាអន្តរជាតិ

**Madrid Guide** – http://www.wipo.int/madrid/en/guide/
សេចក្តីណែនាំរបស់អង្គការ WIPO ចំពោះការចុះបញ្ជីម៉ាកជាអន្តរជាតិ

**Madrid Member Profiles Database** – http://www.wipo.int/madrid/memberprofiles/#/
ទិន្នន័យគ្រប់គ្រងដោយអង្គការ WIPO ដែលផ្តល់ព័ត៌មានស្តីពីនីតិវិធី និងការអនុវត្តដែលទាក់ទងនឹងអានុភាពនៃការចុះបញ្ជីជាអន្តរជាតិនៅក្នុងសមាជិកសមាភាពម៉ាឌ្រីដ

**Madrid Monitor** – http://www.wipo.int/madrid/monitor/en/
សាវាអេឡិចត្រូនិករបស់អង្គការ WIPO ដែលផ្តល់ច្រកចូលទៅមើលព័ត៌មានអំពីម៉ាកទាំងអស់ដែលបានចុះបញ្ជីក្រោមប្រព័ន្ធម៉ាឌ្រីដ

**TMclass** – http://euipo.europa.eu/ec2/
ឧបករណ៍អេឡិចត្រូនិកដែលសម្រួលដល់ការកំណត់អត្តសញ្ញាណ និងការចាត់ថ្នាក់នៃ
ទំនិញនិងសេវានៃការចុះបញ្ជីម៉ាកនៅក្នុងការិយាល័យចុះបញ្ជីម៉ាកចំនួន ៧៣

**TMview** – https://www.tmdn.org/tmview/welcome
វេទិកាព័ត៌មានដែលផ្តល់ច្រកចូលមើទិន្នន័យអំពីម៉ាកជាង ៥១,៩លាន ពីការិយាល័យចុះបញ្ជីម៉ាកចំនួន ៦២

**WIPO Gazette of International Marks** – http://www.wipo.int/madrid/monitor/en/#gazettnd/
ការបោះពុម្ពផ្សាយប្រចាំសប្តាហ៍របស់ប្រព័ន្ធម៉ាឌ្រីដជាផ្លូវការដែលមានទិន្នន័យថ្មីៗទាក់ទងនឹងការចុះបញ្ជីជាអន្តរជាតិ ការបន្តការចុះបញ្ជីជាអន្តរជាតិសាឡើងវិញ ការជ្រើសរើសយកបន្ទាប់ និងការកែប្រែដែលជះឥទ្ធិពលដល់ការចុះបញ្ជីដែលមានស្រាប់។

**WIPO Lex** – http://www.wipo.int/wipolex/en/index.jsp
ទិន្នន័យជាសកលដែលផ្តល់ច្រកចូលមើលព័ត៌មានស្របច្បាប់អំពីកម្មសិទ្ធិបញ្ញា (សន្ធិសញ្ញា ច្បាប់ បទបញ្ញា)

**WIPO User Account** – https://www3.wipo.int/wipoaccounts/en/usercenter/public/register.js
គណនីអ្នកប្រើប្រាស់ដែលផ្តល់ច្រកចូលមើលសេវាមួយចំនួនរបស់អង្គការ WIPO ដែលមានសុវត្ថិភាព ដូចជា ការគ្រប់គ្រងថតផ្ទុកឯកសារម៉ាឌ្រីដ (MPM) ដែលអនុញ្ញាតឱ្យអ្នកគ្រប់គ្រងថតផ្ទុកឯកសារការចុះបញ្ជីម៉ាកជាអន្តរជាតិរបស់អ្នក។

ជាទូទៅសម្រាប់ព័ត៌មានថ្មីៗអំពីប្រព័ន្ធម៉ាឌ្រីដ សូមមើលអាសយដ្ឋានដូចខាងក្រោម
**https://www.wipo.int/madrid/en/**

ARISE+

ASEAN Intellectual Property Rights



# ពិធីសារទីក្រុង ម៉ាឌ្រីដ